







# គោលការណ៍ណែនាំ អាស៊ានស្តីពីការអភិវឌ្ឍ កសិរុក្ខកម្ម

មន្ត្រីជាន់ខ្ពស់អាស៊ានស្តីពីព្រៃឈើ

២០១៨

asean

one vision
one identity
one community

# គោលការណ៍ណែនាំ
# អាស៊ានស្ដីពីការអភិវឌ្ឍ
# កសិរុក្ខកម្ម

## មន្ត្រីជាន់ខ្ពស់អាស៊ានស្ដីពីព្រៃឈើ
## ២០១៨

អគ្គលេខាធិការដ្ឋានអាស៊ាន
រដ្ឋធានីហ្សាកាតា

The Association of Southeast Asian Nations (ASEAN) was established on 8 August 1967. The Member States are Brunei Darussalam, Cambodia, Indonesia, Lao PDR, Malaysia, Myanmar, Philippines, Singapore, Thailand and Viet Nam.

The ASEAN Secretariat is based in Jakarta, Indonesia.

**For inquiries, contact:**
The ASEAN Secretariat
Community Relations Division (CRD)
70A Jalan Sisingamangaraja
Jakarta 12110, Indonesia
Phone: (62 21) 724-3372, 726-2991
Fax: (62 21) 739-8234, 724-3504
E-mail: public@asean.org

Catalogue-in-Publication Data

ASEAN Guidelines for Agroforestry Development
Jakarta, ASEAN Secretariat, May 2019

630.059
1. ASEAN – Agriculture – Forestry
2. Sustainable Development – SDG

ISBN 978-602-5798-35-1

ISBN 978-602-5798-35-1

9 786025 798351

[ASEAN] Association of Southeast Asian Nations. 2019. ASEAN Guidelines for Agroforestry Development [in Khmer]. Authors: Catacutan DC, Finlayson RF, Gassner A, Perdana A, Lusiana B, Leimona B, Simelton E, Öborn I, Galudra G, Roshetko JM, Vaast P, Mulia R, Lasco RL, Dewi S, Borelli S, Yasmi Y. Jakarta, Indonesia: ASEAN Secretariat.

**ASEAN: A Community of Opportunities for All**

Translated into Khmer by Translation Services Cambodia (TS Cambodia)
The original English version of this publication is kept by ASEAN Secretariat, Jakarta

The text of this publication may be freely quoted or reprinted, provided proper acknowledgement is given and a copy containing the reprinted material is sent to the Community Relations Division (CRD) of the ASEAN Secretariat, Jakarta.

General information on ASEAN appears online at the ASEAN Website: www.asean.org

Copyright Association of Southeast Asian Nations (ASEAN) 2019.
All rights reserved.

# បុព្វកថា

គោលការណ៍ណែនាំអាស៊ានស្តីពីការអភិវឌ្ឍកសិរុក្ខកម្ម គឺចំណុចគោលដ៏សំខាន់មួយឆ្ពោះទៅរកការបង្កើនវិបុលភាព ការភ្ជាប់ទំនាក់ទំនង ការបង្កើតភាពធន់ទ្រាំ និងសន្តិសុខសុវត្ថិភាពរបស់ប្រជាជននៃបណ្តារដ្ឋជាសមាជិកអាស៊ាន។ និយាយជារួម គោលការណ៍ណែនាំទាំងនេះ បង្កើតឡើងនូវក្របខណ្ឌមួយដែលនាំឲ្យមានការអភិវឌ្ឍអាចលេចចេញជារូបរាងឡើង។

គោលការណ៍ណែនាំនេះ គឺជាសមិទ្ធផលនៃចក្ខុវិស័យ និងផែនការយុទ្ធសាស្ត្រសម្រាប់កិច្ចសហប្រតិបត្តិការអាស៊ានក្នុងផ្នែកស្បៀងអាហារ កសិកម្ម និងព្រៃឈើ ឆ្នាំ2016-2025 ដែលបានអនុម័តយល់ព្រមដោយរដ្ឋមន្ត្រីកសិកម្ម និងព្រៃឈើអាស៊ានក្នុងឆ្នាំ2016។ ការអនុម័តយល់ព្រមនេះ នាំទៅដល់ការធ្វើសេចក្តីសម្រេចបង្កើតគោលការណ៍ណែនាំសម្រាប់ការអភិវឌ្ឍកសិរុក្ខកម្ម នៅក្នុងរដ្ឋជាសមាជិកអាស៊ាន តាមរយៈដំណើរការនៃកិច្ចពិភាក្សាពិគ្រោះយោបល់ជាច្រើននៅទូទាំងតំបន់ជាមួយភាគីពាក់ព័ន្ធ មិនត្រឹមតែពីផ្នែកកសិកម្ម និងព្រៃឈើប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងវិស័យដទៃផ្សេងទៀតផងដែរ ដូចជា ផ្នែកការប្រែប្រួលអាកាសធាតុ ថាមពល និងទឹកជាដើម។

យើងសង្ឃឹមថា សេចក្តីណែនាំនេះ នឹងបង្កើនល្បឿនកិច្ចសហប្រតិបត្តិការពហុវិស័យ និងការសម្របសម្រួលក្នុងចំណោមវិស័យផ្សេងៗ (ភូមិបាល សេដ្ឋកិច្ច ទឹក ថាមពល កសិកម្ម ព្រៃឈើ ចំណីអាហារ បសុសត្វ និងជលផល) នៅក្នុងចំណោមរដ្ឋជាសមាជិកអាស៊ាន។

យើងក៏សង្ឃឹមផងដែរថា គោលការណ៍ណែនាំនេះ នឹងជំរុញឲ្យមានការបង្កើតគោលនយោបាយនិងកម្មវិធីនានាដែលផ្តោតជាសំខាន់លើផ្នែកកសិរុក្ខកម្មនៅក្នុងបណ្តារដ្ឋជាសមាជិក

ដែលនឹងរួមចំណែកដល់ការលើកកម្ពស់ជីវភាពរស់នៅ និងការបង្កើនមូលដ្ឋានទ្រព្យធនរបស់កសិកររាប់សិបលាននាក់នៅក្នុងតំបន់តាមរយៈការផ្គត់ផ្គង់ស្បៀងអាហារ ដែលពួកគេផលិតបាន ហើយស្របពេលជាមួយគ្នានោះចូលរួមលើកកម្ពស់បរិស្ថាន និងបង្កើតភាពធន់ទ្រាំដល់វិស័យនានាក្នុងការប្រយុទ្ធប្រឆាំងទៅនឹងហេតុការណ៍អាក្រក់មួយចំនួនដែលពុំបានព្រៀងទុកមុនដែលបង្កឡើងដោយការប្រែប្រួលអាកាសធាតុ។ បន្ថែមលើនេះ យើងរំពឹងទុកថា គោលការណ៍ណែនាំនេះ នឹងពន្លឿនកិច្ចសហប្រតិបត្តិការឲ្យបានតែប្រសើរឡើងបន្ថែមទៀតរវាងរដ្ឋជាសមាជិក នៅក្នុងការចែករំលែកបទពិសោធន៍ក្នុងការបង្កើតគោលនយោបាយ និងការអភិវឌ្ឍបច្ចេកទេស លើកកម្ពស់ការដោះដូរផលិតផលកសិរុក្ខកម្មឆ្លងព្រំដែនឲ្យបានកាន់តែច្រើនបន្ថែមទៀត និងជំរុញការធ្វើឲ្យប្រសើរឡើងនូវសេវាកម្មប្រព័ន្ធអេកូឡូស៊ី។ ចំណុចទាំងអស់នេះ នឹងគាំទ្រដល់ការរួមបញ្ចូលគ្នាយ៉ាងជិតស្និទនិងឆាប់រហ័សនៅក្នុងការសម្រេចឲ្យបាននូវចក្ខុវិស័យនៃសហគមន៍សេដ្ឋកិច្ចអាស៊ាន។

អាស៊ាន សារទរចំពោះជំនួយបច្ចេកទេសពីមជ្ឈមណ្ឌលកសិរុក្ខកម្មពិភពលោក (ICRAF) និងអង្គការស្បៀងអាហារនិងកសិកម្ម (FAO) នៃអង្គការសហប្រជាជាតិ ដែលបានជួយសម្របសម្រួលដល់ដំណើរការនៅក្នុងកិច្ចសហប្រតិ

បត្តិការជាមួយដៃគូជាច្រើនមកពីទីភ្នាក់ងាររដ្ឋាភិបាលថ្នាក់ជាតិ
ស្ថាប័នសិក្សាធិការនិងស្រាវជ្រាវជាតិ
ក្នុងតំបន់ និងអន្តរជាតិ អង្គការក្រៅរដ្ឋាភិបាល និងក្រុមសង្គមស៊ីវិល។ យើងក៏សូមថ្លែងអំណរគុណផងដែរសម្រាប់ស្មារតីភាពជាអ្នកដឹកនាំ ការយកចិត្តទុកដាក់ និងកិច្ចសហប្រតិបត្តិការនៃក្រុមការងារ

អាស៊ានស្តីពីសហគមន៍ព្រៃឈើ និងការគាំទ្របច្ចេកទេសតាមរយៈកម្មវិធីភាពជាដៃគូអាស៊ាន-ស្វីសស្តីពីសហគមន៍ព្រៃឈើនិងការប្រែប្រួលអាកាសធាតុ ដែលមានការគាំទ្រពីរដ្ឋាភិបាលប្រទេសស្វីស។ យើងក៏សូមថ្លែងអំណរគុណផងដែរដល់ក្រុមអ្នកជំនាញមេគង្គស្តីពីកសិរុក្ខកម្មសម្រាប់សន្តិសុខស្បៀង
និងអាហារូបត្ថម្ភ
កសិកម្មប្រកបដោយនិរន្តរភាព
និងការស្តារលទ្ធភាពដី ដែលជាផ្នែកមួយនៃគំនិតផ្តួចផ្តើមបណ្តាញកសិកម្មអន្តរជាតិស្វីស សម្រាប់ការគាំទ្រជាបន្តបន្ទាប់របស់ពួកគេក៏ដូចជាការចូលរួមចំណែកក្នុងកិច្ចដំណើរការ

នេះផងដែរ។ ជាចុងក្រោយ
យើងទទួលស្គាល់ថា ប្រសិនបើគ្មានការជំរុញលើកទឹកចិត្ត និងការអ្នកដឹកនាំនៃបណ្តាក្រសួងនានានៃរដ្ឋជាសមាជិក សេចក្តីណែនាំនេះក៏នឹងពុំអាចលេចចេញលទ្ធផលផ្លែផ្កាបាននោះដែរ។

ដោយមានក្រុមជាច្រើនដូចជាក្រុមអ្នកចូលរួមចំណែក និងក្រុមអ្នកគាំទ្រ
ទាំងពីខាងរដ្ឋាភិបាល
អង្គការមិនមែនរដ្ឋាភិបាល និងសង្គមស៊ីវិល ខ្ញុំជឿជាក់ថា គោលការណ៍ណែនាំនេះ នឹងជួយដល់ការពន្លឿនការអនុវត្តកសិរុក្ខកម្មឲ្យបាននៅទូទាំងតំបន់អាស៊ាន និងទទួលបានផលប្រយោជន៍ជាច្រើននៅក្រោយការអនុវត្តនេះ។

**មន្ត្រីជាន់ខ្ពស់អាស៊ានស្តីពីព្រៃឈើ** (ASOF)

# សេចក្តីថ្លែងអំណរគុណ

អាស៊ាន សូមថ្លែងអំណរគុណចំពោះការប្តេជ្ញាចិត្តនិងការខិតខំប្រឹងប្រែងរបស់អ្នកនិពន្ធ អ្នកចូលរួមចំណែក និងអ្នកត្រួតពិនិត្យកិច្ចការ និងអ្នកប្រឹក្សាយោបល់នៃគោលការណ៍ណែនាំនេះ ដែលមានឈ្មោះនិងស្ថាប័នរាយនាមដូចខាងក្រោម និងអរគុណចំពោះភាគីពាក់ព័ន្ធដទៃផ្សេងទៀតនៅក្នុងកិច្ចដំណើរការនៃការពិគ្រោះយោបល់នៅទូទាំងតំបន់ទាំងមូល។

ជាពិសេស យើងសូមទទួលស្គាល់ការដឹកនាំសំខាន់ៗនៃក្រុមការងារអាស៊ានស្តីពីសហគមន៍ព្រៃឈើ ដែលបានដើរតួជាកម្លាំងចលករដ៏សំខាន់ក្នុងការជំរុញឲ្យគោលការណ៍ណែនាំនេះលេចចេញជារូបរាងឡើង។

យើងក៏សូមថ្លែងអំណរគុណផងដែរដល់លេខាធិការដ្ឋាននៃកម្មវិធីភាពជាដៃគូអាស៊ាន-ស្វីសស្តីពីសហគមន៍ព្រៃឈើនិងការប្រែប្រួលអាកាសធាតុ សម្រាប់ការសម្របសម្រួលដល់ការចូលរួមចំណែករបស់ដៃគូពាក់ព័ន្ធនៅក្នុងគោលការណ៍ណែនាំនេះ។

យើងក៏សូមអរគុណផងដែរចំពោះមនុស្សជាង 100 នាក់ មកពីរដ្ឋជាសមាជិកអាស៊ាន រួមមានអ្នកបង្កើតគោលនយោបាយ ក្រុមកសិករ និងសហករណ៍ ក្រុមគ្រប់គ្រងព្រៃឈើនៅតាមសហគមន៍ អ្នកអនុវត្តការងារ អ្នកជំនាញបច្ចេកទេស និងអ្នកស្រាវជ្រាវ ដែលបានចូលរួមនៅការប្រឹក្សាពិគ្រោះយោបល់លើកដំបូងធ្វើឡើងនៅក្នុងសន្និសីទលើកទី 7 របស់ក្រុមការងារអាស៊ានស្តីពីសហគមន៍ព្រៃឈើ នៅក្នុងទីក្រុងឈៀងម៉ៃ ប្រទេសថៃ ពីថ្ងៃ 12-14 ខែមិថុនា ឆ្នាំ2017។ ការប្រឹក្សាពិគ្រោះយោបល់នេះផ្តោតជាសំខាន់លើគោលបំណង និងខ្លឹមសារទូទៅនៃគោលការណ៍ណែនាំនេះ

ដោយកំណត់នូវមូលដ្ឋានសម្រាប់ការអភិវឌ្ឍនាពេលក្រោយៗទៀត។ ជាចុងក្រោយ យើងសូមសម្តែងនូវអំណរគុណយ៉ាងកក់ក្តៅជាទីបំផុតចំពោះ មជ្ឈមណ្ឌលកសិរុក្ខកម្មពិភពលោក (ICRAF) សម្រាប់ការដឹកនាំការរៀបចំគោលការណ៍ណែនាំនេះ និងការសម្របសម្រួលដល់អ្នករួមចំណែកខាងបច្ចេកទេស អ្នកត្រួតពិនិត្យកិច្ចការ និងអ្នកប្រឹក្សាយោបល់។

## អ្នកនិពន្ធ

### មជ្ឈមណ្ឌលកសិរុក្ខកម្មពិភពលោក (ICRAF)

Delia C. Catacutan, Robert Finlayson, Anja Gassner, Aulia Perdana, Betha Lusiana, Beria Leimona, Elisabeth Simelton, Ingrid Öborn, Gamma Galudra, James M. Roshetko, Philippe Vaast, Rachmat Mulia, Rodel Lasco និង Sonya Dewi

### អង្គការស្បៀងអាហារនិងកសិកម្មនៃអង្គការសហប្រជាជាតិ (FAO)

Simone Borelli និង Yurdi Yasmi

# អ្នកត្រួតពិនិត្យកិច្ចការ និងអ្នកចូលរួមចំណែក

## អ្នកជំនាញស្ថាប័ន

មជ្ឈមណ្ឌលមនុស្សនិងព្រៃឈើ (RECOFTC) មជ្ឈមណ្ឌលសម្រាប់ការស្រាវជ្រាវព្រៃឈើអន្តរជាតិ កម្មវិធីដោះដូរផលិតផលអនុផលព្រៃឈើ មជ្ឈមណ្ឌលក្នុងតំបន់អាស៊ីអាគ្នេយ៍សម្រាប់ការសិក្សា និងការស្រាវជ្រាវថ្នាក់ឧត្ដមសិក្សាក្នុងផ្នែកកសិកម្ម, បណ្ដាញស្រាវជ្រាវនិងអប់រំផ្នែកកសិរុក្ខកម្មហ្វីលីពីន

## អ្នកជំនាញ

- បណ្ឌិត Ir. Budiman Achmad
- បណ្ឌិត Sanudin
- បណ្ឌិត Muhamad Siarudin
- បណ្ឌិត Ramon Razal
- Eva Fauziyah S.Hut, អនុបណ្ឌិត
- លោក Eduardo Queblatin
- អ្នកនាង Rowena Cabahug

## ក្រុមចូលរួមសំខាន់នៃក្រុមការងារអាស៊ានស្ដីពីសហគមន៍ព្រៃឈើ

*ព្រុយណេដារូសាឡឹម៖* អ្នកនាង Noralinda Hj Ibrahim
ប្រធានស្ដីទីនៃនាយកដ្ឋានព្រៃឈើ
ក្រសួងធនធានសំខាន់ៗ និងទេសចរណ៍

*កម្ពុជា៖* លោក ឡុង រត្តនៈកុមារ
អនុប្រធាននាយកដ្ឋាន នៃនាយកដ្ឋានព្រៃឈើ និងព្រៃឈើសហគមន៍
រដ្ឋបាលព្រៃឈើនៃក្រសួងកសិកម្ម រុក្ខាប្រម៉ាញ់ និងនេសាទ

*ឥណ្ឌូនេស៊ី៖* បណ្ឌិត Bambang Supriyanto, អគ្គនាយកនៃអគ្គនាយកដ្ឋានព្រៃឈើសហគមន៍ និងភាពជាដៃគូបរិស្ថាននៃក្រសួងបរិស្ថាននិងរុក្ខាប្រម៉ាញ់

*ឡាវ៖* បណ្ឌិត Oupakone Alounsavath, ប្រធានអង្គភាពគ្រប់គ្រងផលិតផលអនុផលព្រៃឈើ និងព្រៃឈើភូមិដ្ឋាន នាយកដ្ឋានព្រៃឈើ ក្រសួងកសិកម្មនិងរុក្ខាប្រម៉ាញ់

*ម៉ាឡេស៊ី៖* បណ្ឌិត Megat Sany Megat Ahmad Supian, អង្គភាពគ្រប់គ្រងជីវៈចម្រុះ និងព្រៃឈើ,
ក្រសួងធនធានធម្មជាតិនិងបរិស្ថាន

*មីយ៉ាន់ម៉ា៖* បណ្ឌិត Ei Ei Swe Hlaing, ជំនួយការនាយក វិទ្យាស្ថានស្រាវជ្រាវព្រៃឈើ នាយកដ្ឋានព្រៃឈើ ក្រសួងធនធានធម្មជាតិ និងអភិរក្សបរិស្ថាន

ហ្វីលីពីន៖ លោក Nonito M. Tamayo, ប្រធានការិយាល័យគ្រប់គ្រងព្រៃឈើ នាយកដ្ឋានបរិស្ថាននិងធនធានធម្មជាតិ

*សិង្ហបុរី៖* លោក Hassan Ibrahim, អ្នកគ្រប់គ្រងជាន់ខ្ពស់ផ្នែកជីវៈចម្រុះ (ភាវៈរស់)
អង្គភាពមជ្ឈមណ្ឌលជាតិជីវៈចម្រុះ
គណៈកម្មការឧទ្យានជាតិ, សួនរុក្ខជាតិសិង្ហបុរី

*ថៃ៖* បណ្ឌិត Komsan Rueangritsarakul, មន្ត្រីបច្ចេកទេសព្រៃឈើ កម្រិតជំនាញវិជ្ជាជីវៈ
ការិយាល័យគ្រប់គ្រងព្រៃឈើសហគមន៍
នាយកដ្ឋានព្រៃឈើហ្លួង

*វៀតណាម៖* លោក Dinh Van Tuyen, មន្ត្រី
អង្គភាពគ្រប់គ្រងនិងការពារព្រៃឈើ
នាយកដ្ឋានការពារព្រៃឈើ រដ្ឋបាលព្រៃឈើវៀតណាមក្រសួងកសិកម្មនិងអភិវឌ្ឍន៍ជនបទ

## ក្រុមអ្នកជំនាញមេគង្គស្ដីពីកសិរុក្ខកម្មសម្រាប់សន្តិសុខស្បៀង និងអាហារូបត្ថម្ភ កសិកម្មប្រកបនិរន្តរភាព និងការស្ដារលទ្ធភាពដី

Andrew Noble, Anja Gassner, Bao Huy, David Gritten, Delia C. Catacutan, Dian Sukmajaya, Doris Capistrano, Ei Ei Swe Hliang, Elisabeth Simelton, Göran Bergkvist, Horst Weyerhaeuser,

Ingrid Öborn, Kim Soben, Long Ratanakoma, Mai Van Trinh, Maria Estrella A. Penunia, Niall O'Connor, Ngo The An, Nguyen Van Bo, Robert Finlayson, Ronnakorn Triraganon, Sararin Phaengam, Sigrun Dahlin, Stepha McMullin, Srichai Saengcharnchai, Tran Minh Tien, Yurdi Yasmi

## អ្នកប្រឹក្សាយោបល់

Dian Sukmajaya, មន្ត្រីជាន់ខ្ពស់នៃអង្គភាពស្បៀងអាហារ កសិកម្ម និងព្រៃឈើ អគ្គនាយកដ្ឋានអភិវឌ្ឍន៍តាមផ្នែក នាយកដ្ឋានសហគមន៍សេដ្ឋកិច្ចអាស៊ាន អគ្គលេខាធិការដ្ឋានអាស៊ាន Doris Capistrano, អ្នកប្រឹក្សាយោបល់ជាន់ខ្ពស់កម្មវិធីភាពជាដៃគូអាស៊ាន-ស្វីសស្តីពីសហគមន៍ព្រៃឈើនិងការប្រែប្រួលអាកាសធាតុ

# មាតិកា


1. សាវតារ និងវិសាលភាពនៃ គោលការណ៍ណែនាំនេះ ........ 1
2. កម្មវត្ថុនៃគោលការណ៍ណែនាំនេ ........ 3
3. អ្នកប្រើប្រាស់គោលដៅ ........ 4
4. គោលការណ៍មគ្គទេសក៍ណែនាំ ........ 6

4.1. គោលការណ៍ស្ថាប័ន ........ 6

គោលការណ៍ទី 1៖ បង្កើតបរិស្ថានអនុគ្រោះ ........ 6

គោលការណ៍ទី 2៖ ធានានូវសមត្ថភាព ស្ថាប័នដែលមានប្រសិទ្ធភាព ........ 7

គោលការណ៍ទី 3៖ គាំទ្រដល់កិច្ចសហប្រតិបត្តិការ និងការធ្វើសេចក្តីសម្រេចចិត្តតាមបែបចូលរួមឲ្យមានប្រសិទ្ធភាព ........ 8

4.2. គោលការណ៍សេដ្ឋកិច្ច ........ 9

គោលការណ៍ទី 4៖ ទទួលស្គាល់តម្លៃទំនិញ និងសេវាកម្មអេកូឡូស៊ី ........ 9

គោលការណ៍ទី 5៖ បង្កើតបរិស្ថានអនុគ្រោះសម្រាប់ការវិនិយោគកសិរុក្ខកម្ម និងទីផ្សារ ........ 10

4.3. គោលការណ៍បរិស្ថាន ........ 11

គោលការណ៍ទី 6៖ ថែរក្សានិងលើកកម្ពស់សេវាកម្មអេកូឡូស៊ីនៅតាមកសិដ្ឋាន និងមាត្រាដ្ឋានតំបន់ទេសភាព ........ 11

គោលការណ៍ទី 7៖ ការយល់ដឹង និង ការគ្រប់គ្រងតុល្យភាពផលិតផល ........ 12

4.4. គោលការណ៍សង្គមវប្បធម៌ ........ 12

គោលការណ៍ទី 8៖ ទទួលស្គាល់និងគោរពដល់ចំណេះដឹង ប្រពៃណី និងជម្រើសក្នុងមូលដ្ឋាន ........ 12

គោលការណ៍ទី 9៖ គាំទ្រសមភាពយេនឌ័រ និងបរិយាប័ន្នសង្គម ........ 13

គោលការណ៍ទី 10៖ ធានាការការពារនិងសិទ្ធិកាន់កាប់ដីធ្លី ........ 14

4.5. គោលការណ៍រៀបចំបច្ចេកទេស ........ 15

គោលការណ៍ទី 11៖ រៀបចំជម្រើសកសិរុក្ខកម្មផ្អែកតាមបរិបទ ........ 15

គោលការណ៍ទី 12៖ ជ្រើសរើសសមាសធាតុកសិរុក្ខកម្មតាមបែបចូលរួម ........ 16

4.6. គោលការណ៍ ទំនាក់ទំនង និង មាត្រដ្ឋាន ........ 18

គោលការណ៍ទី 13៖ ផ្សព្វផ្សាយពីចំណោះដឹងកសិរុក្ខកម្មប្រកបដោយប្រសិទ្ធភាពe... 18

គោលការណ៍ទី 14៖ ការធ្វើផែនការសម្រាប់ មាត្រដ្ឋាន និងនិរន្តរភាព ........ 18

5. ការគិតពិចារណាអំពីការអនុវត្ត ....................................................................20
5.1. តួនាទីស្ថាប័ន និងការរៀបចំ ....................................................................20
5.2. ការធ្វើផែនការ និងការផ្តល់ ហិរញ្ញប្បទាន ....................................................................21
5.3. ការស្រាវជ្រាវ និងការរៀនសូត្រមិនចេះឈប់ ....................................................................22
5.4. ការគ្រប់គ្រងតាមដាន និងការវាយតម្លៃ ....................................................................23
5.5. ការគ្រប់គ្រងចំណេះដឹង ....................................................................24
ឧបសម្ព័ន្ធ 1 ការបង្កើតគោលការណ៍ណែនាំ ....................................................................25
ឧបសម្ព័ន្ធ 2 ម្រេចស ....................................................................27
ឧបសម្ព័ន្ធ 3 បរិបទអន្តរជាតិនៃគោលការណ៍ណែនាំនេះ ....................................................................29
ឧបសម្ព័ន្ធ 4 ឯកសារជំនួយបន្ថែម ....................................................................32

# ជំពូក ១
# សារៈតារ និងវិសាលភាពនៃគោលការណ៍ណែនាំនេះ

ចក្ខុវិស័យនិងផែនការយុទ្ធសាស្ត្រសម្រាប់កិច្ចសហប្រតិបត្តិការអាស៊ាននៅក្នុងផ្នែកស្បៀងអាហារ កសិកម្ម និងព្រៃឈើ ឆ្នាំ2016-2025 ដូចបានអនុម័តនៅក្នុងកិច្ចប្រជុំរដ្ឋមន្ត្រីកសិកម្ម និងព្រៃឈើអាស៊ានលើកទី 38 ឆ្នាំ2016 មានគោលបំណងក្នុងការធានាថា "ធនធានព្រៃឈើត្រូវបានគ្រប់គ្រងប្រកបដោយនិរន្តរភាពនៅកម្រិតតំបន់ទេសភាព ដើម្បីបំពេញតាមតម្រូវការសង្គមទាំងផ្នែកសេដ្ឋកិច្ចសង្គមនិងវប្បធម៌ សម្រាប់មនុស្សជំនាន់នេះនិងជំនាន់ក្រោយ និងដើម្បីរួមចំណែកជាវិជ្ជមានដល់ការអភិវឌ្ឍប្រកបដោយចីរភាព។"

ដោយមានការទទួលស្គាល់នូវការរួមចំណែកនៃកសិរុក្ខកម្មនៅក្នុងការសម្រេចឲ្យបាននូវសន្តិសុខស្បៀង ធ្វើឲ្យប្រសើរឡើងនូវការបន្សាំនិងការកាត់បន្ថយផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ និងការកាត់បន្ថយការខូចគុណភាពដី និងដើម្បីសម្រេចបាននូវគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពជាច្រើន ជាមួយនឹងកិច្ចខិតខំប្រឹងប្រែងដើម្បីពង្រឹងការភ្ជាប់ទំនាក់ទំនងរវាងផ្នែកព្រៃឈើនិងផលិតកម្មស្បៀងតាមរយៈវិធីសាស្ត្រគ្រប់គ្រងទេសភាពចម្រុះ ក៏ដូចជាដើម្បីធ្វើឲ្យប្រសើរឡើងនូវការគ្រប់គ្រងព្រៃឈើប្រកបដោយនិរន្តរភាព កិច្ចប្រជុំមន្ត្រីជាន់ខ្ពស់ស្តីពីព្រៃឈើអាស៊ានលើកទី 20 បានឯកភាពគ្នាក្នុងការបង្កើតគោលការណ៍ណែនាំស្តីពីកសិរុក្ខកម្មនេះឡើង។ កិច្ចប្រជុំរដ្ឋមន្ត្រីកសិកម្ម និង ព្រៃឈើអាស៊ានលើកទី 39 បានអនុម័តនូវអនុសាសន៍ក្នុងការបង្កើតគោលការណ៍ណែនាំ ដែលជាគន្លឹះក្នុងការចែករំលែកនូវកិច្ចសហប្រតិបត្តិការអាស៊ាននៅក្នុងផ្នែកព្រៃឈើនៅក្នុងឆ្នាំ2018។

មជ្ឈមណ្ឌលកសិរុក្ខកម្មពិភពលោក[1] ត្រូវបានស្នើឡើងតាមរយៈក្រុមការងារអាស៊ានស្តីពីសហគមន៍ព្រៃឈើ ដើម្បីធ្វើការរៀបចំ (រួមគ្នាជាមួយអង្គការស្បៀងអាហារនិងកសិកម្មនៃអង្គការសហប្រជាជាតិ (FAO) និងភាពជាដៃគូ[2] នៃគម្រោងភាពជាដៃគូអាស៊ាន-ស្វីសស្តីពីសហគមន៍ព្រៃឈើនិងការប្រែប្រួលអាកាសធាតុ) នូវបណ្តុំនៃគោលការណ៍នានាដើម្បីគាំទ្រដល់ការអភិវឌ្ឍកសិរុក្ខកម្មនៅតាមបណ្តារដ្ឋជាសមាជិកអាស៊ាន។ គោលការណ៍ណែនាំនេះ ត្រូវបានចាត់ទុកគោលការណ៍ចាំបាច់ដើម្បីសម្រេ

1 មជ្ឈមណ្ឌលកសិរុក្ខកម្មពិភពលោក គឺជាសមាជិករបស់ CGIAR ដែលជាអង្គការភាពជាដៃគូសាកលសម្រាប់អនាគតសន្តិសុខស្បៀង និងជាដៃគូនៃគម្រោងភាពជាដៃគូអាស៊ាន-ស្វីសស្តីពីសហគមន៍ព្រៃឈើ និងការប្រែប្រួលអាកាសធាតុ។

2 មជ្ឈមណ្ឌលសម្រាប់ការស្រាវជ្រាវព្រៃឈើអន្តរជាតិ, RECOFTC: មជ្ឈមណ្ឌលមនុស្សនិងព្រៃឈើ, កម្មវិធីដោះដូរផលិតផលអនុផលព្រៃឈើ, និងមជ្ឈមណ្ឌលក្នុងតំបន់អាស៊ីអាគ្នេយ៍សម្រាប់ការសិក្សានិងការស្រាវជ្រាវថ្នាក់ឧត្តមសិក្សាក្នុងផ្នែកកសិកម្ម។

ចបាននូវចក្ខុវិស័យនិងផែនការ យុទ្ធសាស្រ្តក្នុងផ្នែកស្បៀងអាហារ កសិកម្ម និងព្រៃឈើនៃតំបន់អាស៊ាន ជាពិសេសយុទ្ធសាស្រ្ត Thrust 4 ការបង្កើនភាពធន់ទ្រាំទៅនឹងការប្រែប្រួលអាកាសធាតុ គ្រោះធម្មជាតិ និងគ្រោះថ្នាក់បន្ទាន់ផ្សេងទៀត កម្មវិធីសកម្មភាព 5, ពាក់ព័ន្ធនឹង "ការពង្រីកបន្ថែមប្រព័ន្ធកសិរុក្ខកម្មដែលមានភាពធន់ទ្រាំដែលមានលក្ខណៈសមស្របផ្នែកអេកូឡូស៊ីនិងសេដ្ឋកិច្ច។

ការពិភាក្សាពិគ្រោះយោបល់ជាមួយភាគីពាក់ព័ន្ធដទៃផ្សេងទៀត ដូចជា អ្នកស្រាវជ្រាវផ្នែកសិក្សាធិការ អ្នកអនុវត្តការងារ អ្នកជំនាញបច្ចេកទេស តំណាងពីរដ្ឋាភិបាលថ្នាក់ជាតិផ្នែកព្រៃឈើ កសិកម្ម និងបរិស្ថាន និងសមាគមកសិករ ត្រូវបានសម្របសម្រួលធ្វើឡើងចាប់តាំងពីខែមិថុនា ឆ្នាំ 2017 មកម្ល៉េះ។ អ្នកនិពន្ធនិងអ្នកចូលរួមចំណែកចង់ធ្វើការបញ្ជាក់បន្ថែមថា គោលការណ៍ណែនាំនេះ ត្រូវបានរៀបចំបង្កើតឡើងដើម្បីជានាថាការអភិវឌ្ឍកសិរុក្ខកម្ម គឺពឹងផ្អែកទៅលើបរិបទពិសេសផ្ទាល់ខ្លួននៃរដ្ឋជាសមាជិកអាស៊ាន។ លក្ខខណ្ឌសង្គមសេដ្ឋកិច្ច គោលនយោបាយ និងបរិស្ថាននៃរដ្ឋជាសមាជិកនីមួយៗ នឹងត្រូវយកមកពិចារណាដូចៗគ្នានៅក្នុងការរៀបចំអន្តរាគមន៍ផ្នែកកសិរុក្ខកម្មណាមួយ។

គោលការណ៍ណែនាំនេះ មានបំណងចង់អនុវត្តចំពោះដីគ្រប់ប្រទេសទាំងអស់ ឬប្រព័ន្ធអេកូឡូស៊ីគោលដៅសម្រាប់អន្តរាគមន៍ផ្នែកកសិរុក្ខកម្ម ជាមួយរដ្ឋជាសមាជិកអាស៊ាន មិនថានៅតំបន់ព្រៃឈើ កសិដ្ឋាន តំបន់ទីជម្រាល តំបន់ខ្ពង់រាប តំបន់ទំនាប តំបន់ឆ្នេរ តំបន់ដីសើម ឬតំបន់មានរុក្ខជាតិពុកផុយនោះទេ។ គោលការណ៍នេះ ពុំមែនជាគោលការណ៍ណែនាំផ្នែកបច្ចេកទេសសម្រាប់ការបង្កើតកសិរុក្ខកម្មនោះទេ ប៉ុន្តែផ្ទុយទៅវិញ វាគឺជាក្របខណ្ឌមួយសម្រាប់ការសម្របសម្រួល កិច្ចពិភាក្សានៅក្នុងការរៀបចំគោលនយោបាយ កម្មវិធី គម្រោង និងការវិនិយោគក្នុងផ្នែកកសិរុក្ខកម្មរវាងនិងក្នុងបណ្ដារដ្ឋជាសមាជិកអាស៊ាន។ ការអនុវត្តគោលការណ៍ណែនាំនេះ គឺធ្វើឡើងដោយការស្ម័គ្រចិត្ត និងមិនបានដាក់បន្ថែម ឬជំនួសកិច្ចព្រមព្រៀងឬអនុសញ្ញា ច្បាប់និងគោលនយោបាយជាតិផ្លូវការដែលមានស្រាប់អ្វីនោះទេ ប៉ុន្តែត្រូវបង្កើតឡើងស្របទៅនឹងគ្រោងការពហុវិស័យអាស៊ានស្ដីពីការប្រែប្រួលអាកាសធាតុ៖ កសិកម្មនិងព្រៃឈើឆ្ពោះទៅរកសន្តិសុខស្បៀងy[3], និងគោលការណ៍ណែនាំអាស៊ានទៅតាមវិស័យដែលពាក់ព័ន្ធនឹងកសិរុក្ខកម្ម[4]។

បើទោះបីជាគោលការណ៍និងគោលការណ៍ណែនាំដែលមានរៀបរាប់នៅក្នុងឯកសារនេះ មានបំណងធ្វើឡើងសម្រាប់រដ្ឋជាសមាជិកអាស៊ានក៏ពិតមែន ក៏ប៉ុន្តែវាតំណាងឲ្យទស្សនៈទូលំទូលាយដែលអាចយកទៅអនុវត្តបានដោយរដ្ឋផ្សេងទៀតនៅក្រៅតំបន់អាស៊ានផងដែរ។

---

3 គ្រោងការពហុវិស័យស្ដីពីការប្រែប្រួលអាកាសធាតុ ត្រូវបានបង្កើតឡើងស្ថិតក្រោមខ្លឹមសារនៃកិច្ចប្រជុំមន្ត្រីជាន់ខ្ពស់អាស៊ានស្ដីពីកសិកម្មនិងព្រៃឈើ ដើម្បីផ្ដល់នូវយន្តការសម្រាប់សកម្មភាពដែលមានការសម្របសម្រួល ដើម្បីដោះស្រាយការគំរាមកំហែងចំពោះសន្តិសុខស្បៀងដោយសារការប្រែប្រួលអាកាសធាតុ។ គ្រោងការនេះផ្ដោតជាសំខាន់លើវិស័យកសិកម្ម ជលផល និងព្រៃឈើ និងមានគោលបំណងដើម្បីបន្តវិធីសាស្រ្តអន្តរវិស័យសម្រាប់ការបង្កើតនិងការអនុវត្តគោលនយោបាយប្រកបដោយប្រសិទ្ធភាព

4 សេចក្ដីណែនាំក្នុងតំបន់អាស៊ានសម្រាប់ការជំរុញលើកកម្ពស់ការអនុវត្តកសិកម្មឆ្លាតវៃខាងអាកាសធាតុ គោលការណ៍ណែនាំស្ដីពីយែនឌ័រ គោលការណ៍ណែនាំអាស៊ានស្ដីពីការវិនិយោគដោយទំនួលខុសត្រូវ។

ជំពូក ២

# កម្មវត្ថុនៃ គោលការណ៍ណែនាំនេះ

1) ជំរុញលើកកម្ពស់តួនាទីកសិរុក្ខកម្មដើម្បីសម្រេចបានជាបន្តបន្ទាប់នូវសមិទ្ធផលសេដ្ឋកិច្ច បរិស្ថាន និងសង្គមនៅកម្រិតកសិដ្ឋាន គ្រួសារ និងតំបន់ទេសភាព។

2) ណែនាំដល់ការបង្កើតគោលនយោបាយ យុទ្ធសាស្ត្រ និងកម្មវិធីកសិរុក្ខកម្មនៃរដ្ឋជាសមាជិកអាស៊ាន និងជំរុញការវិនិយោគពីវិស័យឯកជន ក៏ដូចជាការបង្កើតកម្មវិធីសិក្សានិងកម្មវិធីអប់រំផ្នែកកសិរុក្ខកម្ម។

3) ជួយរដ្ឋជាសមាជិកអាស៊ានឲ្យសម្រេចបាននូវគោលដៅពាក់ព័ន្ធនឹងសន្តិសុខស្បៀង ការអភិវឌ្ឍបៃតង និងការអភិវឌ្ឍប្រកបដោយចីរភាព ការកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ ការស្តារគុណភាពដី ការការពារតំបន់ជម្រាល សមភាពយេនឌ័រ ព្រៃឈើសហគមន៍/សង្គម ការបន្ស៊ាំនិងការកាត់បន្ថយការប្រែប្រួលអាកាសធាតុ និងជារួមគឺដើម្បីសម្រេចបានគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព។

4) ពង្រឹងភាពជាដៃគូក្នុងចំណោមរដ្ឋជាសមាជិកអាស៊ាន តាមរយៈសកម្មភាពរួមគ្នាស្តីពីការអភិវឌ្ឍកសិរុក្ខកម្ម។

# ជំពូក ៣
# អ្នកប្រើប្រាស់គោលដៅ

អ្នកប្រើប្រាស់ដៃគោលដៅសំខាន់នៃគោលការណ៍ណែនាំនេះគឺអ្នកបង្កើតគោលនយោបាយនៃរដ្ឋជាសមាជិកអាស៊ាន និងបន្ទាប់មកទៀតគឺអ្នកធ្វើផែនការកម្មវិធី និង/ឬគម្រោងនានានៅកម្រិតថ្នាក់ជាតិនិងកម្រិតថ្នាក់ក្រោមជាតិ វិនិយោគិនក្នុងស្រុកនិងក្រៅស្រុក ស្ថាប័នសម្រាប់ការសិក្សានៅឧត្តមសិក្សា និងអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកនិងអន្តរជាតិដែលពាក់ព័ន្ធនៅក្នុងការអភិវឌ្ឍកសិរុក្ខកម្ម។ គោលការណ៍ណែនាំនេះ ក៏អាចប្រើប្រាស់បានផងដែរដោយក្រុមសង្គមស៊ីវិលសម្រាប់គោលបំណងសម្រាប់ការតស៊ូមតិ។

**កសិរុក្ខកម្ម** គឺជាអន្តរទំនាក់ទំនងរវាងផ្នែកកសិកម្មនិងព្រៃឈើ រួមបញ្ចូលនូវការប្រើប្រាស់រុក្ខជាតិនៅក្នុងវិស័យកសិកម្មផងដែរ។ នេះរួមបញ្ចូលនូវការដាំដុះរុក្ខជាតិនៅតាមកសិដ្ឋាន និងតំបន់ទេសភាព កសិកម្មនៅក្នុងតំបន់ព្រៃ និងព្រៃឈើតាមតំបន់ជាយៗ និងផលិតកម្មកសិផលជាដើម។ អន្តរទំនាក់ទំនងរវាងរុក្ខជាតិ និងធាតុផ្សំដទៃទៀតផ្នែកកសិកម្ម ដូចជា បសុសត្វ ផលផល និងវារីជាតិ គឺមានសារៈសំខាន់ណាស់នៅក្នុងកម្រិតនៃមាត្រដ្ឋាន៖ នៅតាមទីវាល (ដែលរុក្ខជាតិនិងដំណាំកសិផលត្រូវបានដាំដុះរួមគ្នា) នៅតាមកសិដ្ឋាន (ដែលរុក្ខជាតិអាចផ្តល់ជាចំណីសត្វសម្រាប់សត្វចិញ្ចឹម ជាថាមពលឥន្ធនៈ ចំណីអាហារ ទីជម្រក ឬប្រាក់ចំណូលពីផលិតផល និងផលិតផលឈើ) និងតំបន់ទេសភាព (ដែលដីកសិកម្មនិងដីព្រៃ ត្រូវបានប្រើប្រាស់រួមគ្នាដើម្បីកំណត់នូវការផ្តល់សេវាកម្មអេកូឡូស៊ី)។ នៅកម្រិតថ្នាក់ជាតិនិងពិភពលោក ផ្នែកព្រៃឈើនិងកសិកម្ម មានទំនាក់ទំនងជាលក្ខណៈប្រព័ន្ធអេកូឡូស៊ី និងទំនាក់ទំនងតាមរយៈគោលនយោបាយនានាពាក់ព័ន្ធនឹងការប្រើប្រាស់ដីធ្លីនិងជំនួញ និងមានសារៈសំខាន់ចំពោះការប្រែប្រួលអាកាសធាតុ និងក្តីបារម្ភផ្នែកបរិស្ថានដទៃផ្សេងទៀត។ កសិរុក្ខកម្ម ប្រកាន់ខ្ជាប់នូវវិធីសាស្ត្រកសិអេកូឡូស៊ី ដែលបញ្ជាក់ពីពហុមុខងារ និងការគ្រប់គ្រងនៃប្រព័ន្ធស្មុគ្រស្មាញ និងការអនុវត្តពហុវប្បកម្ម ជាជាងការផ្តោតសំខាន់តែទៅលើការអនុវត្តឯកវប្បកម្ម។ ពាក្យ "រុក្ខជាតិ" ត្រូវប្រើប្រាស់សំដៅលើដើមឈើ និងចុល្លព្រឹក ភីរេននៀល (រុក្ខជាតិដែលដុះបានជាងពីររដូវលូតលាស់) និងអំបូរត្នោត និងឬស្សី។ ស្រដៀងគ្នានេះដែរ ពាក្យ "កសិកម្ម" ត្រូវបានប្រើប្រាស់ដើម្បីសំដៅលើសកម្មភាពមនុស្ស ដែលធ្វើឡើងក្នុងគោលបំណងផលិតចំណីអាហារ ជាតិសរសៃ និងប្រភពថាមពល តាមរយៈការប្រើប្រាស់ដោយចេតនានិងដោយមានការគ្រប់គ្រងទៅលើរុក្ខជាតិ សត្វ និងប្រភេទវារីជាតិ។ កសិរុក្ខកម្ម បានបញ្ជាឲ្យឃើញនូវអត្ថប្រយោជន៍នានាក្នុងផ្នែកសន្តិសុខស្បៀង និងអាហារូបត្ថម្ភសម្រាប់គ្រួសារ ការផ្គត់ផ្គង់ថាមពលជាអុសដុត ការបន្សាំនិងការកាត់បន្ថយការប្រែប្រួលអាកាសធាតុ ការធ្វើនិយ័តកម្មតំបន់ជម្រាល និងការស្តារគុណភាពដី និងការធ្វើឲ្យប្រសើឡើងនូវកសិជីវៈចម្រុះ និង

ចំណុចដទៃផ្សេងទៀត។ កសិរុក្ខកម្ម ក៏ជួយដល់កសិករក្នុងការកាត់បន្ថយហានិភ័យសេដ្ឋកិច្ចនិងបរិស្ថាន ដោយផ្តល់នូវធនធានប្រាក់ចំណូលសំខាន់ៗសម្រាប់គ្រួសារនៅតាមទីជនបទ ជាពិសេសនៅពេលប្រឈមនឹងបញ្ហាការប្រែប្រួលអាកាសធាតុ។ កសិករនៅក្នុងតំបន់អាស៊ីអាគ្នេយ៍ បានអនុវត្តកសិរុក្ខកម្មនេះជាយូរមកហើយ ហើយប្រភេទនៃកសិរុក្ខកម្ម អាចមានភាពខុសប្លែកគ្នាទៅតាមប្រភពដើមនៃតំបន់នោះ (ឧបសម្ព័ន្ធ 2)។

គេបានទទួលស្គាល់ជាទូទៅនូវសារៈសំខាន់នៃព្រៃឈើចំពោះសុខភាពភពផែនដី ប៉ុន្តែគេក៏មិនត្រូវមើលរំលងពីសារៈសំខាន់នៃរុក្ខជាតិដែលដុះនៅក្រៅតំបន់ព្រៃ ថាមានតួនាទីសំខាន់ក្នុងការស្តារតំបន់ទេសភាព និងដើម្បីសម្រេចបាននូវគោលដៅជាតិនិងអន្តរជាតិដ៏ធំនៅក្នុងវិស័យដែលគ្របដណ្តប់ដោយផ្នែកកសិកម្ម។ មានវិធីជាច្រើនដើម្បីធ្វើការស្តារឡើងវិញនូវតំបន់ទេសភាពដែលបាត់បង់គុណភាព ប៉ុន្តែមានវិធីតែមួយចំនួនតូចប៉ុណ្ណោះដែលអាចស្តារឡើងវិញនូវជីវៈចម្រុះ និងប្រព័ន្ធអេកូឡូស៊ីបាន និងអាចផ្តល់នូវចំណីអាហារ និងសន្តិសុខស្បៀងនិងអាហារូបត្ថម្ភ ប្រាក់ចំណូល និងសេវាកម្មអេកូឡូស៊ីផ្សេងទៀត តាមរយៈការចូលរួម និងការផ្តល់អំណាចដល់សហគមន៍ក្នុងមូលដ្ឋានកសិរុក្ខកម្មអាចផ្តល់ជូនបាន។ នៅពេលប្រើប្រាស់សម្រាប់ជាមធ្យោបាយក្នុងការស្តារឡើងវិញនូវព្រៃឈើនិងតំបន់ទេសភាព កសិរុក្ខកម្មអាចធ្វើឲ្យប្រសើរឡើងនូវលក្ខណៈពិសេសរបស់ដីផ្នែករូបសាស្រ្ត គីមីសាស្រ្ត និងជីវសាស្រ្ត ដែលនាំឲ្យមានការបង្កើតសមាសធាតុសរីរាង្គរបស់ដីនិងលទ្ធភាពបង្កបង្កើនផល ដោយធ្វើឲ្យប្រសើរឡើងនូវវដ្តសារធាតុចិញ្ចឹម ការគ្រប់គ្រងសំណឹកដី និងការគ្រប់គ្រងទឹក។ ការស្តារឡើងវិញនូវតំបន់ទេសភាពដែលបាត់បង់គុណភាពដីតាមរយៈការអនុវត្តកសិរុក្ខកម្ម អាចបង្កើនភាពធន់ទ្រាំរបស់សហគមន៍ទៅនឹងបញ្ហានានា រួមទាំងគ្រោះរាំងស្ងួត និងកង្វះខាតស្បៀង និងជួយបន្សាំនិងកាត់បន្ថយការប្រែប្រួលអាកាសធាតុ (FAO 2017)។

បច្ចុប្បន្ននេះ កសិរុក្ខកម្មកំពុងត្រូវបានគេទទួលស្គាល់ថាជាមធ្យោបាយដ៏សំខាន់មួយដើម្បីសម្រេចបានអនុសញ្ញា ក្របខណ្ឌ និងគោលដៅអន្តរជាតិនានាដែលរដ្ឋជាសមាជិកអាស៊ានមានការប្តេជ្ញាចិត្តខ្ពស់ដើម្បីអនុវត្តឲ្យបានជោគជ័យ (ឧបសម្ព័ន្ធ 3)។ ក្រៅពីនេះ កិច្ចព្រមព្រៀងទីក្រុងបារីស ដែលបានចូលជាធរមាននៅថ្ងៃទី 4 ខែវិច្ឆិកា ឆ្នាំ 2016 ផ្តល់នូវក្របខណ្ឌសាកលមួយសម្រាប់ការធ្វើឲ្យប្រសើរឡើងនូវកសិរុក្ខកម្ម ដោយសាររុក្ខជាតិនៅតំបន់ព្រៃនិងនៅតាមកសិដ្ឋាន បានដើរតួជាចំណុចស្នូលសម្រាប់ការបន្សាំនិងការកាត់បន្ថយការប្រែប្រួលអាកាសធាតុ។ ដោយសារសមត្ថភាពរុក្ខជាតិក្នុងការចាប់យកសារធាតុកាបូន កសិរុក្ខកម្មអាចរួមចំណែកដល់ការសម្រេចបាននូវការចូលរួមចំណែកដើម្បីអនុវត្តអនុសញ្ញាក្របខណ្ឌសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុសម្រាប់រដ្ឋជាសមាជិកអាស៊ាន។ កសិរុក្ខកម្ម ក៏អាចជាមធ្យោបាយដ៏មានសារៈសំខាន់ផងដែរក្នុងការសម្រេចបាននូវគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព ដែលជួយលុបបំបាត់ភាពស្រេកឃ្លាន កាត់បន្ថយភាពក្រីក្រ គាំទ្រដល់សមភាពយេនឌ័រ និងបរិយាប័ន្នសង្គម ផ្តល់នូវថាមពលដែលមានតម្លៃថោកសមរម្យ និងថាមពលស្អាត ការពារជីវិតនៅលើដី កែប្រែគុណភាពដី និងប្រយុទ្ធប្រឆាំងនឹងការប្រែប្រួលអាកាសធាតុ (ឧបសម្ព័ន្ធ 2)។

ជំពូក ៤

# គោលការណ៍មគ្គុទេសក៍ណែនាំ

គោលការណ៍មគ្គុទេសក៍ណែនាំនេះ គឺមានភាពប្រទាក់ក្រឡាគ្នា ដែលតំណាងឲ្យទស្សនៈទូលំទូលាយមួយ ដែលណែនាំដល់ការបង្កើតអន្តរាគមន៍កសិរុក្ខកម្ម (ឧទាហរណ៍ គោលនយោបាយ កម្មវិធី គម្រោង និងការវិនិយោគអាជីវកម្ម) នៅទូទាំងរដ្ឋជាសមាជិកអាស៊ាន នៅគ្រប់កាលៈទេសៈទាំងអស់ ដោយពុំគិតពីការផ្លាស់ប្ដូរគោលដៅ និងយុទ្ធសាស្ត្រនៃបណ្ដាប្រទេសនីមួយឡើយ។ ផ្នែកនេះផ្ដល់នូវគោលការណ៍ណែនាំសំខាន់ៗសម្រាប់គោលការណ៍នីមួយៗ។

## 4.1. គោលការណ៍ស្ថាប័ន

### គោលការណ៍ទី 1៖ បង្កើតបរិស្ថានអនុគ្រោះ

ដោយគិតពិចារណាអំពីបញ្ហាកង្វះខាតស្ថាប័នផ្នែកកសិរុក្ខកម្មនៅក្នុងប្រទេសជាច្រើននៅក្នុងតំបន់អាស៊ីអាគ្នេយ៍ពិតជាមានសារៈសំខាន់ណាស់ក្នុងការផ្ដល់នូវបរិស្ថានស្ថាប័ន និងគោលនយោបាយអនុគ្រោះ ដែលអាចសម្រួលដល់ការបង្កើតគោលនយោបាយ កម្មវិធី និងការវិនិយោគលើផ្នែកកសិរុក្ខកម្មបាន។ នៅគ្រប់កាលៈទេសៈទាំងអស់ គោលការណ៍អភិបាលកិច្ចល្អដែលអនុម័តដោយផ្នែកផ្សេងៗគ្នា ដែលរួមបញ្ចូលទាំងទំនួលខុសត្រូវអភិបាលកិច្ចលើការកាន់កាប់ដីធ្លី ជលផល និងព្រៃឈើរបស់ FAO (តម្លាភាព សមភាពគណនេយ្យ បរិយាប័ន្ន)[5] ត្រូវអនុលោមទៅតាមគ្រប់កម្រិតទាំងអស់នៃការធ្វើផែនការ ការធ្វើសេចក្ដីសម្រេចចិត្ត និងការអនុវត្តអន្តរាគមន៍កសិរុក្ខកម្ម។ គោលការណ៍ណែនាំនេះ រួមបញ្ចូលនូវចំណុចជាអាទិ៍ដូចខាងក្រោម។

**គោលការណ៍ណែនាំ** 1.1. អនុវត្តទៅតាមអនុសញ្ញា ក្របខណ្ឌកិច្ចព្រមព្រៀង យុទ្ធសាស្ត្រ និងកម្មវិធីអន្តរជាតិនិងក្នុងតំបន់ដែលមានស្រាប់នៅពេលបង្កើតកម្មវិធី គម្រោង ឬគោលនយោបាយកសិរុក្ខកម្ម។

**គោលការណ៍ណែនាំ** 1.2. ត្រួតពិនិត្យច្បាប់ បទប្បញ្ញត្តិ យុទ្ធសាស្ត្រ និងកម្មវិធីជាតិនានាពាក់ព័ន្ធនឹងកសិរុក្ខកម្ម និងបង្កើតគោលនយោបាយថ្មីៗ ឬធ្វើការកែប្រែលើគោលនយោបាយដែលមានស្រាប់ ដើម្បីធានាថាការអភិវឌ្ឍកសិរុក្ខកម្ម មានគោលនយោបាយច្បាស់លាស់ និងមានការគាំទ្រដោយផ្លូវច្បាប់។

**គោលការណ៍ណែនាំ** 1.3. បង្កើតស្ថាប័ន "ជំនាញ" សម្រាប់ផ្នែកកសិរុក្ខកម្ម។ វាយតម្លៃរចនាសម្ព័ន្ធស្ថាប័នដែលមានស្រាប់ និងការរៀបចំស្ថាប័នសមស្របមួយ ឬបង្កើតស្ថាប័នថ្មីមួយជាមួយក្រសួងពាក់ព័ន្ធនៅក្នុងរដ្ឋជាសមាជិកអាស៊ាន ដែលទទួលបន្ទុកលើការអភិវឌ្ឍកសិរុក្ខកម្ម ដោយមានការបែងចែកភារកិច្ច តួនាទី និងទំនួលខុសត្រូវឲ្យបានច្បាស់លាស់។

**គោលការណ៍ណែនាំ** 1.4. បង្កើតកម្មវិធី យុទ្ធសាស្ត្រ ឬផែនទីបង្ហាញផ្លូវផ្នែកកសិរុក្ខ

5 ទំនួលខុសត្រូវអភិបាលកិច្ចលើការកាន់កាប់ ដីធ្លី ជលផល និងរុក្ខាប្រម៉ាញ់នៅក្នុងបរិបទនៃសន្តិសុខស្បៀងជាតិ៖ http://www.fao.org/docrep/016/ i2801e/i2801e .pdf

កម្មថ្នាក់ជាតិ និងគាំទ្រដល់ការអភិវឌ្ឍនៅកម្រិតថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ។

**គោលការណ៍ណែនាំ** 1.5. ផ្តល់នូវលក្ខខណ្ឌនិងនីតិវិធីអនុគ្រោះនានា ដែលលើកទឹកចិត្តនិងគាំទ្រដល់ការជ្រើសយកកសិរុក្ខកម្មដូចជាសុវត្ថិភាពនៃការកាប់ដីធ្លីការលើកកម្ពស់ការចូលទៅកាន់ទីផ្សារ និងហេដ្ឋារចនាសម្ព័ន្ធដែលបានកែលម្អ។

**គោលការណ៍ណែនាំ** 1.6. ស្វែងរកមធ្យោបាយផ្សេងៗដើម្បីផ្តល់នូវការគាំទ្រដែលសមស្រប និងបន្តផ្តល់មូលនិធិដល់ការអភិវឌ្ឍកសិរុក្ខកម្ម។

## គោលការណ៍ទី 2៖ ធានានូវសមត្ថភាពស្ថាប័នដែលមានប្រសិទ្ធភាព

យោងទៅលើគោលការណ៍ទី 1 ការអភិវឌ្ឍសមត្ថភាពស្ថាប័ន ទីភ្នាក់ងារ ឬនាយកដ្ឋានទទួលបន្ទុក ឬស្ថាប័ន ទីភ្នាក់ងារ ឬនាយកដ្ឋានថ្មី ជាមួយក្រសួងពាក់ព័ន្ធ និងដៃគូសំខាន់ៗរបស់អង្គភាពទាំងនេះ គឺជាចំណុចចាំបាច់ដើម្បីចែករំលែកចំណេះដឹងផ្ទេរបច្ចេកវិទ្យា ធ្វើការស្រាវជ្រាវផ្តល់សេវាគាំពារ និងជំរុញដល់ការធ្វើផែនការប្រកបដោយប្រសិទ្ធភាព។ គោលការណ៍ណែនាំនេះ រួមបញ្ចូលនូវចំណុចជាអាទិ៍ដូចខាងក្រោម។

**គោលការណ៍ណែនាំ** 2.1 ពង្រឹងសមត្ថភាពស្ថាប័នដែលទទួលបន្ទុកផ្នែកកសិរុក្ខកម្មនិងដៃគូរបស់ស្ថាប័ននៅកម្រិតថ្នាក់ជាតិនិងកម្រិតថ្នាក់ក្រោមជាតិ ដើម្បីចែករំលែកចំណេះដឹងនិងជំនាញឲ្យមានប្រសិទ្ធភាពផ្តល់នូវការណែនាំបច្ចេកទេសសម្របសម្រួលដល់ការធ្វើផែនការ និងការធ្វើសេចក្តីសម្រេចចិត្តដែលមានការចូលរួមនៅកម្រិតជាច្រើន និងគ្រប់គ្រងតាមដានលទ្ធផលនិងផលប៉ះពាល់នានា។

**គោលការណ៍ណែនាំ** 2.2. កំណត់និងកៀងគរបុគ្គលនិងអ្នកជំនាញស្ថាប័នដើម្បីធ្វើឲ្យប្រសើរឡើងនូវសមត្ថភាពបច្ចេកទេសសម្រាប់ការអភិវឌ្ឍកសិរុក្ខកម្មនៅកម្រិតជាច្រើន។

**គោលការណ៍ណែនាំ** 2.3. លើកកម្ពស់សមត្ថភាពស្រាវជ្រាវនៅកម្រិតថ្នាក់ជាតិ ដើម្បីធ្វើការស្រាវជ្រាវកសិរុក្ខកម្មតាមបែបចូលរួម និងផ្សារភ្ជាប់ចំណេះដឹងទៅនឹងគោលនយោបាយតាមរយៈការចូលរួមនៅក្នុងគោលនយោបាយនិងដំណើរការនៃការធ្វើផែនការ។

**គោលការណ៍ណែនាំ** 2.4. លើកកម្ពស់ការពង្រីកសមត្ថភាពថ្នាក់ជាតិដើម្បីសម្របសម្រួលដល់ការផ្ទេរចំណេះដឹង និងជំនាញក្នុងចំណោមភាគីពាក់ព័ន្ធទាំងអស់ គាំទ្រដល់កិច្ចពិភាក្សា ធ្វើផែនការកម្មវិធីនិងគម្រោងកសិរុក្ខកម្ម និងរៀបចំជម្រើសកសិរុក្ខកម្មសម្រាប់បរិបទផ្សេងៗគ្នា។

**គោលការណ៍ណែនាំ** 2.5. ពង្រឹងកិច្ចសហប្រតិបត្តិការសម្រាប់ការស្រាវជ្រាវ និងការផ្សព្វផ្សាយរវាងការស្រាវជ្រាវថ្នាក់ជាតិ និងប្រព័ន្ធចែកចាយបន្ថែម និងការស្រាវជ្រាវអន្តរជាតិ និងអង្គការអភិវឌ្ឍន៍នានា រួមទាំងបណ្ឌិតសភាផងដែរ។

**គោលការណ៍ណែនាំ** 2.6. លើកទឹកចិត្តឲ្យមានការអប់រំកសិរុក្ខកម្មតាមរយៈការផ្តល់ការគាំទ្រដល់មហាវិទ្យាល័យ និងសាកលវិទ្យាល័យនានានៅក្នុងការបង្កើតកម្មវិធីសិក្សាផ្នែកកសិរុក្ខកម្មតាមរយៈបណ្តាញការអប់រំនៅឧត្តមសិក្សាដែលមានស្រាប់នៅក្នុងតំបន់។

**គោលការណ៍ណែនាំ** 2.7. កំណត់ពីតម្រូវការជាក់លាក់របស់ភាគីពាក់ព័ន្ធផ្សេងៗ និងផ្ត

ល់នូវសេវាគាំទ្រតាមការចង់បានសម្រាប់តម្រូវការនានារបស់ម្ចាស់ដីធំៗ (ម្ចាស់ដីសម្បទាន ក្រុមហ៊ុន កសិដ្ឋាន) និងម្ចាស់ដីតូចៗ6។[6].

### គោលការណ៍ទី 3៖ គាំទ្រដល់កិច្ចសហប្រតិបត្តិការ និងការធ្វើសេចក្ដីសម្រេចចិត្តតាមបែបចូលរួមឲ្យមានប្រសិទ្ធភាព

ត្រូវគិតពិចារណាអំពីលក្ខណៈពហុទិដ្ឋភាពនៃកសិរុក្ខកម្ម បញ្ញត្តិដែលពាក់ព័ន្ធ និងទំនាក់ទំនងផ្សេងទៀតជាមួយផ្នែកកសិកម្ម រុក្ខាប្រម៉ាញ់ និងផ្នែកដទៃផ្សេងទៀតនៃការប្រើប្រាស់ដី, តំបន់ទេសភាព-កម្រិតនៃអន្តរទំនាក់ទំនង និងការផ្សារភ្ជាប់ជាមួយវិស័យដទៃផ្សេងទៀត (ឧទាហរណ៍ បសុសត្វ ថាមពល វារីវប្បកម្ម ទឹក ការប្រែប្រួលអាកាសធាតុ និងជីវភាពរស់នៅក្នុងតំបន់ជនបទ) វិធីសាស្ត្រគ្រប់គ្រងតំបន់ទេសភាព ដើម្បីធ្វើផែនការអន្តរាគមន៍កសិរុក្ខកម្ម និងកិច្ចសហប្រតិបត្តិការអន្តរវិស័យ និងការធ្វើការសេចក្ដីសម្រេចចិត្តរួមគ្នា ដូចមានចែងនៅក្នុងគ្រោងការពហុវិស័យអាស៊ានស្ដីពីការប្រែប្រួលអាកាសធាតុ៖ កសិកម្មនិងព្រៃឈើឆ្ពោះទៅរកសន្តិសុខស្បៀង គឺត្រូវការជាចាំបាច់សម្រាប់ការអភិវឌ្ឍកសិរុក្ខកម្មប្រកបដោយប្រសិទ្ធភាព។ គោលការណ៍ណែនាំនេះ រួមបញ្ចូលនូវចំណុចជាអាទិ៍ដូចខាងក្រោម។

**គោលការណ៍ណែនាំ**3.1.លើកកម្ពស់វិធីសាស្ត្រតាមបែបចូលរួម និងការចូលរួមពីភាគីពាក់ព័ន្ធទាំងអស់នៅកម្រិតសមស្របនៃការធ្វើផែនការនិងការធ្វើសេចក្ដីសម្រេចចិត្តសម្រាប់ការធ្វើផែនការរួមគ្នា ការកំណត់គោលដៅ និងការអនុវត្តអន្តរាគមន៍កសិរុក្ខកម្ម ជាពិសេសនៅកម្រិតម្ចាស់ដីតូចៗ។ ភាគីពាក់ព័ន្ធអាចរួមបញ្ចូលនូវអ្នកបង្កើតគោលនយោបាយ និងអ្នកធ្វើផែនការមកពីវិស័យពាក់ព័ន្ធនានាដូចជា ឧស្សាហកម្មឯកជន វិនិយោគិន និងម្ចាស់ដីសម្បទាន អ្នកស្រាវជ្រាវ អង្គការក្រៅរដ្ឋាភិបាល ម្ចាស់ឧបត្ថម្ភ និងដៃគូអន្តរជាតិ អង្គការនិងសហករណ៍កសិករ ក្រុមជនជាតិភាគតិច និងក្រុមជនជាតិដើម និងក្រុមស្ត្រី និងក្រុមអ្នកផលិត (ភ្ជាប់ទៅនឹងគោលការណ៍ទី 8)។

**គោលការណ៍ណែនាំ** 3.2. ធានាថាអន្តរាគមន៍កសិរុក្ខកម្ម និងផលិតផលនិងសេវាកម្មនៃអន្តរាគមន៍នេះ មានការយល់ដឹងច្បាស់លាស់ និងត្រូវបានរួមបញ្ចូលនៅក្នុងយុទ្ធសាស្ត្រឆ្លើយតបតាមវិស័យ។

**គោលការណ៍ណែនាំ** 3.3. រៀបចំអន្តរាគមន៍កសិរុក្ខកម្មនៅក្នុងបរិបទនៃតំបន់ទេសភាពទាំងមូល និងដែលពាក់ព័ន្ធនឹងការផ្លាស់ប្តូរនាពេលអនាគតនៅក្នុងរបបអាកាសធាតុ ក៏ដូចជាការផ្លាស់ប្តូរក្នុងផ្នែកសេដ្ឋកិច្ចនិងគោលនយោបាយ ដើម្បីធានាថាផលប៉ះពាល់នៅនឹងកន្លែងផ្ទាល់ និងក្រៅកន្លែង ផលប៉ះពាល់រយៈពេលខ្លីនិងវែង ត្រូវបានយកមកពិចារណា គ្រប់គ្រង និងតាមដានស្របទៅតាមស្តង់ដាសង្គម សេដ្ឋកិច្ច និងបរិស្ថាន ដែលបានអនុម័តទទួលយកដោយរដ្ឋជាសមាជិកអាស៊ាន (ភ្ជាប់ទៅនឹងគោលការណ៍ទី 11)។

**គោលការណ៍ណែនាំ** 3.4. រួមបញ្ចូលគ្នានិងផ្សះផ្សារគោលដៅ ផលប្រយោជន៍ និងទំនួលខុសត្រូវដែលតែងមានភាពខុសគ្នាជាញឹកញាប់នៃភាគីព

---

6 សេវាគាំទ្រ អាចរួមបញ្ចូលនូវទិដ្ឋភាពបច្ចេកទេសមួយចំនួនក្នុងផ្នែកកសិរុក្ខកម្ម បច្ចេកទេសក្រោយការប្រមូលផល ការធ្វើទីផ្សារ ឥណទាន និងហិរញ្ញប្បទានជាដើម។

ក់ព័ន្ធនានានៅក្នុងតំបន់ទេសភាពដែលកំណត់គោលដៅសម្រាប់ការអនុវត្តកសិរុក្ខកម្ម ដែលរួមមានជាអាទិ៍ម្ចាស់ដីតូចៗ ក្រុមផលិតខ្នាតតូចនិងខ្នាតធំ ក្រុមព្រៃឈើនៅតាមសហគមន៍ ម្ចាស់ដីសម្បទានធំៗ និងអង្គភាពរដ្ឋាភិបាលជាដើម (ភ្ជាប់ទៅនឹងគោលការណ៍ទី 8, 9, 11)។

**គោលការណ៍ណែនាំ** 3.5. ប្រើប្រាស់ឧបករណ៍កំណត់លំហច្បាស់លាស់ ដើម្បីកំណត់ចំណុចដែលស័ក្តិសមបំផុតសម្រាប់ការអនុវត្តកសិរុក្ខកម្មនៅក្នុងតំបន់ទេសភាព ស្របទៅតាមលក្ខណៈសមស្របផ្នែកបរិស្ថាន សង្គម និងសេដ្ឋកិច្ច ដើម្បីជានានូវអត្ថប្រយោជន៍ជាសក្តានុពល (ភ្ជាប់ទៅនឹងគោលការណ៍ទី 11)[7]។

**គោលការណ៍ណែនាំ** 3.6. គោរព ប្រើប្រាស់ និង/ឬ រួមបញ្ចូលនូវប្រព័ន្ធចំណេះដឹងប្រពៃណីទៅក្នុងការស្រាវជ្រាវបែបវិទ្យាសាស្ត្រ ការធ្វើផែនការ និងការធ្វើសេចក្តីសម្រេចចិត្ត (ភ្ជាប់ទៅនឹងគោលការណ៍ទី 8)។

**គោលការណ៍ណែនាំ** 3.7. ជានានូវការរួមចំណែកនៃកសិរុក្ខកម្មទៅក្នុងគោលដៅក្នុងមូលដ្ឋាន និងភាពស្របគ្នាជាមួយគោលដៅក្របខណ្ឌអាស៊ាន យុទ្ធសាស្ត្រនិងកម្មវិធីសកម្មភាពថ្នាក់ជាតិ ក៏ដូចជាអនុសញ្ញា សន្ធិសញ្ញា កិច្ចព្រមព្រៀង គោលដៅ និងយុទ្ធសាស្ត្រអន្តរជាតិផងដែរ។

## 4.2. គោលការណ៍សេដ្ឋកិច្ច

### គោលការណ៍ទី 4៖ ទទួលស្គាល់តម្លៃទំនិញ និងសេវាកម្មអេកូឡូស៊ី

កសិរុក្ខកម្មផ្តល់អត្ថប្រយោជន៍ជាច្រើនក្នុងទម្រង់ជាទំនិញនិងសេវាកម្មអេកូឡូស៊ីសម្រាប់ទីផ្សារ គ្រួសារ និងបរិស្ថាន។ កសិរុក្ខកម្ម ជាទូទៅគឺជាការអនុវត្តតាមបែបប្រពៃណី ដែលកសិករដើរតួនាទីជាអ្នកត្រួតពិនិត្យកាន់កាប់ដី ដែលពួកគេគប្បីទទួលបានការទទួលស្គាល់ ទទួលរង្វាន់ ឬទទួលសំណងការខូចខាតសម្រាប់ការវិនិយោគរយៈពេលវែង ដូចជាតាមរយៈប្រាក់ចំណូលដោយផ្ទាល់ពីផលិតផលកសិរុក្ខកម្ម និង/ឬតាមរយៈការផ្តល់រង្វាន់សម្រាប់គម្រោងសេវាកម្មអេកូឡូស៊ី។ គោលការណ៍ណែនាំនេះ រួមបញ្ចូលនូវចំណុចជាអាទិ៍ដូចខាងក្រោម។

**គោលការណ៍ណែនាំ** 4.1. លើកកម្ពស់ផលិតផលកសិរុក្ខកម្មគ្រប់ប្រភេទ (ឧទាហរណ៍ ផលិតផលស្រស់ និងផលិតផលសម្រាប់ប្រើប្រាស់និងលក់) ដូចជាការបង្កើតម៉ាកផលិតផលពិសេស និង/ឬវិញ្ញាបនបត្របញ្ជាក់ ដូចជាពាណិជ្ជកម្មស្មើភាព ឬផលិតផល "បៃតង" ជាដើម និងពង្រឹងការគាំទ្រដល់ម្ចាស់ដីតូចៗដើម្បីរួមបញ្ចូល និងដើម្បីសម្រេចបាននូវសេដ្ឋកិច្ចមួយដែលទទួលអត្ថប្រយោជន៍យ៉ាងច្រើនពីខ្សែចង្វាក់តម្លៃកសិរុក្ខកម្ម។

**គោលការណ៍ណែនាំ** 4.2. គោរពចំណេះដឹងក្នុងមូលដ្ឋាន ចំពោះក្នុងការប្រើប្រាស់ផលិតផលកសិរុក្ខកម្មសម្រាប់គោលបំណងនានា ដូចជាសម្រាប់គោល

7 ឧទាហរណ៍ ប្រអប់គន្លឹះសម្រាប់ការគ្រប់គ្រងព្រៃឈើប្រកបដោយចីរភាពរបស់ FAOH(http://www.fao.org/sustainable-forest-management/toolbox/tools/en/) និងប្រអប់គន្លឹះនៃមជ្ឈមណ្ឌលកសិរុក្ខកម្មពិភពលោក (http://www.worldagroforestry.org/output?field_type_tid=756) និងការធ្វើផែនការប្រើប្រាស់ដីសម្រាប់អត្ថប្រយោជន៍បរិស្ថានជាច្រើន (LUMENS:http:// www.worldagroforestry.org/region/sea/publications/detail?pubID=3447)

បំណងសន្តិសុខស្បៀងនិងអាហារូបត្ថម្ភ ពូជជីវសាស្ត្រ និងការធ្វើពាណិជ្ជកម្ម និងជានានូវការបែងចែកអត្ថប្រយោជន៍ស្មើភាពគ្នារវាងភាគីពាក់ព័ន្ធទាំងឡាយ (ភ្ជាប់ទៅនឹងគោលការណ៍ទី 8, 9)។

**គោលការណ៍ណែនាំ** 4.3. ផ្តល់នូវប្រាក់ឧបត្ថម្ភរយៈពេលវែង ប្រាក់ចំណាយ ឬប្រាក់រង្វាន់សម្រាប់សេវាកម្មអេកូឡូស៊ីជាច្រើនដែលផ្តល់ដោយកសិរុក្ខកម្ម ដែលមានសារៈសំខាន់ដល់មុខងារទីជម្រាល ការស្តារគុណភាពដី ការស្រូបទុកកាបូន និងការលើកកម្ពស់ជីវៈចម្រុះ ដែលភាគច្រើន គឺជាផលប្រយោជន៍សាធារណៈ (ភ្ជាប់ទៅនឹងគោលការណ៍ទី 6)។

**គោលការណ៍ណែនាំ** 4.5. រួមបញ្ចូលទិន្នន័យកសិរុក្ខកម្មទៅក្នុងមូលដ្ឋានទិន្នន័យជាតិ ក្នុងតំបន់និងពិភពលោក ដូចជា ទិន្នន័យរុក្ខជាតិនៅតាមកសិដ្ឋាន ការសិក្សាពីប្រភេទនៃកសិរុក្ខកម្មនិងកាបូន ការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយធំៗ របាយភូមិសាស្ត្រ ព័ត៌មានផលិតភាព ប្រាក់ចំណេញ និងការជ្រើសរើស។

### គោលការណ៍ទី 5៖ បង្កើតបរិស្ថានអនុគ្រោះសម្រាប់ការវិនិយោគកសិរុក្ខកម្ម និងទីផ្សារ

ការបង្កើតបរិស្ថានអនុគ្រោះដោយរដ្ឋជាសមាជិកអាស៊ាន ដោយមានការផ្តល់ប្រាក់លើកទឹកចិត្តដោយផ្ទាល់ឬដោយប្រយោល ជំរុញលើកទឹកចិត្ត

ក្រុមហ៊ុន និងវិនិយោគិនកាន់កាប់ដីខ្នាតតូចឲ្យធ្វើការវិនិយោគរយៈពេលវែងនៅក្នុងផ្នែកកសិរុក្ខកម្ម។ ការវិនិយោគបែបនេះ អាចតម្រង់ទិសឆ្ពោះទៅរកទីផ្សារបាន លើកលែងតែក្នុងករណីការផលិតសម្រាប់ប្រើប្រាស់ខ្លួនឯងនៅក្នុងតំបន់មួយចំនួនដែលលទ្ធភាពស្វែងរកទីផ្សារ និងកត្តាផ្សេងទៀត គឺជាឧបសគ្គដ៏ធំ។យន្តការទីផ្សារថ្មីៗ អាចត្រូវការជាចាំបាច់ ប៉ុន្តែអាចមានផលប៉ះពាល់អវិជ្ជមានទៅដល់សង្គមនិងសេដ្ឋកិច្ច ហេតុនេះការបង្កើតបរិស្ថានអនុគ្រោះសម្រាប់ការវិនិយោគកសិរុក្ខកម្ម ត្រូវតែមានភាពស្របគ្នាជាមួយនឹងគោលការណ៍ណែនាំអាស៊ានស្តីពីការវិនិយោគប្រកបដោយទំនួលខុសត្រូវ។ គោលការណ៍ណែនាំនេះ រួមបញ្ចូលនូវចំណុចជាអាទិ៍ដូចខាងក្រោម។

**គោលការណ៍ណែនាំ** 5.1. កំណត់និងបង្កើតគ្រោងការហិរញ្ញប្បទាន រួមទាំងឥណទានគាំទ្រជនក្រីក្រ (ឧទាហរណ៍ មានរយៈពេលសងប្រាក់យូរ និងមានអត្រាការប្រាក់កម្រិតទាប) ដើម្បីគាំទ្រដល់គំរូអាជីវកម្មកសិរុក្ខកម្មសម្រាប់ម្ចាស់ដីខ្នាតតូច និងសហគ្រាសខ្នាតតូចនិងមធ្យម។

**គោលការណ៍ណែនាំ** 5.2. ផ្តល់នូវគោលនយោបាយនានា ដែលគាំទ្រដល់ការវិនិយោគរយៈពេលវែង ដែលមានភាពបត់បែន និងការធ្វើផែនការប្រើប្រាស់ដីនៅកម្រិតថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិដើម្បីផ្តល់ទំនុកចិត្តដល់អ្នកផ្តល់ប្រាក់វិនិយោគនៅក្នុងផ្នែកកសិរុក្ខកម្ម។

**គោលការណ៍ណែនាំ** 5.3. ផ្តល់នូវការគាំទ្របច្ចេកទេស និងការផ្សព្វផ្សាយពាណិជ្ជកម្ម ដើម្បីអភិវឌ្ឍខ្សែចង្វាក់តម្លៃកសិរុក្ខកម្ម និងបង្កើតបណ្តាញទីផ្សារ (ភ្ជាប់ទៅនឹងគោលការណ៍ទី 4)។

**គោលការណ៍ណែនាំ** 5.4. ផ្តល់នូវនីតិវិធីដែលមានតម្លាភាពនិងងាយៗសម្រាប់ធ្វើការកែច្នៃ និងធ្វើទីផ្សារផលិតផលកសិរុក្ខកម្ម ដើម្បីជំរុញការវិនិយោគខ្នាតតូចនិងធំ។

**គោលការណ៍ណែនាំ** 5.5. ដកចេញនូវការបកស្រាយខុសផ្នែកសេដ្ឋកិច្ចដែលកើតចេញពី

វិស័យដទៃផ្សេងទៀតដែលកាត់បន្ថយតម្លៃផលិតផលកសិរុក្ខកម្ម ឬដែលកាត់បន្ថយឱកាសសម្រាប់វិនិយោគិនកសិរុក្ខកម្ម ជាពិសេសម្ចាស់ដីខ្នាតតូច។

**គោលការណ៍ណែនាំ** 5.6. ផ្ដល់នូវប្រាក់ឧបត្ថម្ភលើកទឹកចិត្តជាច្រើនប្រភេទ ទោះដោយផ្ទាល់និងដោយប្រយោលក្ដី សម្រាប់អន្តរាគមន៍កសិរុក្ខកម្មដែលផ្ដល់អត្ថប្រយោជន៍ដល់សង្គម (ភ្ជាប់ទៅនឹងគោលការណ៍ទី 4)។

## 4.3. គោលការណ៍បរិស្ថាន

### គោលការណ៍ទី 6៖ ថែរក្សានិងលើកកម្ពស់សេវាកម្មអេកូឡូស៊ីនៅតាមកសិដ្ឋាន និងមាត្រាដ្ឋានតំបន់ទេសភាព

កសិដ្ឋានកសិរុក្ខកម្ម គឺតែងមានទីតាំងនៅតំបន់ទេសភាពដែលប្រើសម្រាប់គោលបំណងជាច្រើននៅក្នុងពេលតែមួយ។ ក្នុងករណីជាច្រើន កសិដ្ឋានទាំងនោះស្ថិតនៅតំបន់ខ្ពស់រាប និងតំបន់ទីជម្រាលសំខាន់ៗ។ ហេតុនេះ ក្រៅពីការផលិតផលទំនិញ និងផលិតផលនានា ការអនុវត្តកសិរុក្ខកម្ម នឹងមានឥទ្ធិពលក្នុងការផ្ដល់សេវាកម្មអេកូឡូស៊ីជាច្រើនប្រភេទផងដែរ។ ដោយសារមូលហេតុនេះ ការអភិវឌ្ឍកសិរុក្ខកម្ម គប្បីធានាថាសេវាកម្មអេកូឡូស៊ីដែលកើតមានពី

តំបន់ទេសភាពទាំងនេះ ត្រូវបានអភិរក្ស ស្ដារឡើងវិញ និងកែលម្អ។ ការធ្វើផែនការដោយយកចិត្តទុកដាក់ និងការគ្រប់គ្រងបានត្រឹមត្រូវលើផ្នែកកសិរុក្ខកម្ម គប្បីត្រូវផ្សព្វផ្សាយឲ្យបានដឹង ដើម្បីអាចសម្រេចបាននូវអត្ថប្រយោជន៍អេកូឡូស៊ីគោលដៅ ដោយពុំមានធ្វើឲ្យថយចុះនូវអត្ថប្រយោជន៍សេដ្ឋកិច្ចនិងអត្ថប្រយោជន៍ដទៃផ្សេងទៀត។ គោលការណ៍ណែនាំនេះ រួមបញ្ចូលនូវចំណុចជាអាទិ៍ដូចខាងក្រោម។

**គោលការណ៍ណែនាំ** 6.1. ធានាថាអន្តរាគមន៍កសិរុក្ខកម្ម ត្រូវបានរៀបចំផែនការដោយមានគោលដៅ ដើម្បីសម្រេចបាននូវអត្ថប្រយោជន៍ជាច្រើនក្នុងពេលជាមួយគ្នា (អត្ថប្រយោជន៍សេដ្ឋកិច្ច សង្គម និងបរិស្ថាន) នៅកម្រិតជាច្រើនរាប់ចាប់តាំងពីកសិដ្ឋានរហូតដល់កម្រិតតំបន់ទេសភាព (ភ្ជាប់ទៅនឹងគោលការណ៍ទី 3, 11)។

**គោលការណ៍ណែនាំ** 6.2. ទទួលស្គាល់ និងវាយតម្លៃផលវិជ្ជមាននៃកសិរុក្ខកម្មនៅក្នុងការថែរក្សា និងលើកកម្ពស់សេវាកម្មអេកូឡូស៊ី រួមទាំងការស្ដារឡើងវិញនូវមុខងារព្រៃឈើ និងតំបន់ទេសភាព ការស្ដារដីខូចគុណភាព ការកាត់បន្ថយសំណឹកដី ការកាត់បន្ថយការប្រែប្រួលអាកាសធាតុ និងការការប្រយុទ្ធប្រឆាំងនឹងរហោស្ថានកម្ម (ភ្ជាប់ទៅនឹងគោលការណ៍ទី 4, 11)។

**គោលការណ៍ណែនាំ** 6.3. ធ្វើការវាយតម្លៃផលប៉ះពាល់បរិស្ថាននៅមុនពេលអនុវត្ត អន្តរាគមន៍កសិរុក្ខកម្មទ្រង់ទ្រាយធំ រួមទាំងការបង្កើតខ្សែគោលដើម្បីគ្រប់គ្រងឥទ្ធិពលលើសេវាកម្មអេកូឡូស៊ី។

**គោលការណ៍ណែនាំ** 6.4. ជំរុញឲ្យមានការទទួលបានប្រយោជន៍ផ្នែកជីវៈចម្រុះសមស្រប ដើម្បីសំណងសម្រាប់ការខាតបង់ឬការផលប៉ះពាល់ដែលបង្កឡើងដោយការអភិវឌ្ឍកសិរុក្ខកម្ម បន្ទាប់បានអនុវត្តវិធានការកាត់បន្ថយផលប៉ះពាល់រួច។

**គោលការណ៍ណែនាំ** 6.5. បង្កើត និងអនុវត្តវិធានប្រតិបត្តិស្តង់ដារនៅក្នុងការបង្កើតនិងការគ្រប់គ្រងអន្តរាគមន៍កសិរុក្ខកម្ម ដើម្បីធានានូវការរួមចំណែកដល់សេវាកម្មអូកូឡូស៊ី (ភ្ជាប់ទៅនឹងគោលការណ៍ទី 11, 12)។

### គោលការណ៍ទី 7៖ ការយល់ដឹង និង ការគ្រប់គ្រងតុល្យភាពផលិតផល

តុល្យភាពផលិតផល គឺជាតុល្យភាពអត្ថប្រយោជន៍ដែលពុំអាចសម្រេចបាននៅក្នុងពេលតែមួយ។ ការយល់ដឹង និងការគ្រប់គ្រងតុល្យភាពផលិតផល គឺពិតជាមានសារៈសំខាន់ខ្លាំងនៅពេលចាប់ផ្តើមអនុវត្តកសិរុក្ខកម្ម ដែលរុក្ខជាតិ ដំណាំ ត្រី និងសត្វចិញ្ចឹមត្រូវបានគេដាក់បញ្ចូលគ្នាទៅក្នុងចំណែកដីតែមួយ។ តុល្យភាពផលិតផល កើតមានលើលក្ខណៈកាលាកាសរួមគ្នា ដោយក្នុងផ្នែកអាកាសមានពាក់ព័ន្ធនឹងការរៀបចំសមាសធាតុខុសៗគ្នាផ្នែកកសិរុក្ខកម្ម ហើយក្នុងផ្នែកកាលវិញ ការដាក់បញ្ចូលរុក្ខជាតិទៅក្នុងប្រព័ន្ធកសិកម្ម អាចនាំឲ្យមានការបង្កើនពេលវេលាយូរជាងមុននៅចន្លោះការវិនិយោគ និងការទទួលបានផលចំណេញ។ ដើម្បីយល់ដឹង និងគ្រប់គ្រងតុល្យភាពផលិតផលនេះឲ្យបានកាន់តែប្រសើរថែមទៀត គោលការណ៍ណែនាំនេះ រួមបញ្ចូលនូវចំណុចជាអាទិ៍ដូចខាងក្រោម។

**គោលការណ៍ណែនាំ** 7.1. ប្រើប្រាស់វិធីសាស្រ្តតាមបែបចូលរួមដើម្បីយល់ដឹងពីការធ្វើសេចក្តីសម្រេចរបស់អ្នកកាន់កាប់ដីតូចៗ អ្នកកាន់កាប់ដីមធ្យម និងធំ និងក្រុមកសិករសម្រាប់ផលិតកម្មរយៈពេលខ្លីនិងរយៈពេលវែងប្រកបដោយនិរន្តរភាព ដែលគិតពិចារណាលើតម្រូវការខុសៗគ្នារបស់សមាជិកគ្រួសារ (ជាពិសេសស្រ្តីនិងយុវជន) ឧស្សាហកម្ម និងទីផ្សារ (ភ្ជាប់ទៅនឹងគោលការណ៍ទី 3, 11, 12)។

**គោលការណ៍ណែនាំ** 7.2. ប៉ាន់ស្មានទំហំនៃតុល្យភាពពាណិជ្ជកម្មធំៗ និងគាំទ្រដល់ការធ្វើសេចក្តីសម្រេចចិត្តដោយធ្វើការគណនាការខាតបង់ផ្នែកសេដ្ឋកិច្ចនិងបរិស្ថាន និងផលចំណេញនៃអន្តរាគមន៍កសិរុក្ខកម្ម។ ការខាតបង់ គឺជាខ្ទង់ចំណាយពីការវិនិយោគលើដីពលកម្ម និងហិរញ្ញវត្ថុ ហើយចំណែកផលចំណេញ គឺជាអ្វីដែលទទួលបានមកវិញ ដូចជា ផលិតផលរុក្ខជាតិ កសិផល ត្រី និងសត្វចិញ្ចឹម និង/ឬសេវាកម្មអេកូឡូស៊ី (ភ្ជាប់ទៅនឹងគោលការណ៍ទី 4, 6)។

**គោលការណ៍ណែនាំ** 7.3. គិតពិចារណាពីប្រាក់ចំណូលពីមុនរបស់កសិករនិងវិនិយោគិន ជាពិសេសក្នុងអំឡុងពេលឆ្នាំដំបូងនៃការបង្កើតកសិរុក្ខកម្ម និងស្វែងរកវិធីនិងមធ្យោបាយក្នុងការកាត់បន្ថយនិងគ្រប់គ្រងតុល្យភាពពាណិជ្ជកម្ម ដូចជា តាមរយៈឥណទានរយៈពេលវែង អត្រាការប្រាក់ទាប ការកាត់បន្ថយពន្ធ ប្រាក់បុព្វលាភរ៉ាប់រង និងប្រាក់ឧបត្ថម្ភលើកទឹកចិត្តសម្រាប់ការផ្តល់សេវាកម្មអេកូឡូស៊ី (ភ្ជាប់ទៅនឹងគោលការណ៍ទី 4, 5, 6)។

## 4.4. គោលការណ៍សង្គមវប្បធម៌

### គោលការណ៍ទី 8៖ ទទួលស្គាល់និងគោរពដល់ចំណេះដឹងប្រពៃណី និង ជម្រើសក្នុងមូលដ្ឋាន

បទដ្ឋានសង្គម ប្រព័ន្ធគុណតម្លៃវប្បធម៌ និងប្រព័ន្ធចំណេះដឹងក្នុងមូលដ្ឋាន/ប្រពៃណី គប្បីត្រូវយកមកធ្វើការពិចារណានៅក្នុងការធ្វើផែនការ និងការអនុវត្តអន្តរាគមន៍កសិរុក្ខកម្ម។ គោលការណ៍ណែនាំនេះ រួមបញ្ចូលនូវចំណុចជាអាទិ៍ដូចខាងក្រោម។

**គោលការណ៍ណែនាំ** 8.1. ទទួលស្គាល់និងគោរពប្រព័ន្ធប្រពៃណី និងគុណតម្លៃក្នុងមូលដ្ឋាន រួមទាំងចំណេះ

ដឹងនិងការអនុវត្តរបស់ក្រុមជនជាតិភាគតិច ចំពោះសហគមន៍ដែលមានគោលដៅសម្រាប់អន្តរាគមន៍កសិរុក្ខកម្ម (ភ្ជាប់ទៅនឹងគោលការណ៍ទី 4, 10)។

**គោលការណ៍ណែនាំ** 8.2.
ជានាសុវត្ថិភាពការវិនិយោគនៅក្នុងផ្នែកកសិរុក្ខកម្មនៃភាគីពាក់ព័ន្ធតាមរយៈដំណើរការនៃការយល់ព្រមដោយគ្មានការបង្ខិតបង្ខំ និងការយល់ព្រមជាមុនដែលមានព័ត៌មានគ្រប់គ្រាន់ (ភ្ជាប់ទៅនឹងគោលការណ៍ទី 10)[8]។

**គោលការណ៍ណែនាំ** 8.3.
ជានាថាចំណេះដឹងក្នុងស្រុក និងជម្រើសនានាពាក់ព័ន្ធនឹងជម្រើសកសិរុក្ខកម្ម (ឧទាហរណ៍ រុក្ខជាតិ និងកសិផលពូជសត្វបង្កាត់ និងប្រភេទផ្សេងៗ) គោលបំណង និងការអនុវត្ត ត្រូវយកមកគិតពិចារណានៅពេលធ្វើការស្រាវជ្រាវនៅក្នុងអំឡុងពេលធ្វើផែនការនិងធ្វើសេចក្តីសម្រេចចិត្ត (ភ្ជាប់ទៅនឹងគោលការណ៍ទី 3, 4, 10, 11, 12)។

**គោលការណ៍ណែនាំ** 8.4. ទទួលស្គាល់និងលើកឡើងអំពីតម្រូវការពិសេសរបស់ប្រជាពលរដ្ឋសម្រាប់ការបណ្តុះបណ្តាលបច្ចេកវិទ្យា សិទ្ធិកាន់កាប់ដី និងសិទ្ធិលើធនធានហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្ត និងព័ត៌មានទីផ្សារជាពិសេសសម្រាប់ប្រជាជនភាគតិច និងក្រុមបងប្អូនជនជាតិ (ភ្ជាប់ទៅនឹងគោលការណ៍ទី 3)។

**គោលការណ៍ណែនាំ** 8.5.
បង្កើតគោលការណ៍សង្គម សេដ្ឋកិច្ចវប្បធម៌ សម្រាប់ការគ្រប់គ្រងវឌ្ឍនភាពនិងការវាយតម្លៃផលប៉ះពាល់ ក៏ដូចជាសម្រាប់ការអនុលោមទៅតាមច្បាប់សង្គម-សុខុមាលភាព និងគោលការណ៍ណែនាំលើការវិនិយោគដែលអនុម័តដោយរដ្ឋជាសមាជិកអាស៊ាន និងច្បាប់អន្តរជាតិជាធរមាន។

**គោលការណ៍ណែនាំ** 8.6.
បង្ការការបណ្តេញចេញពីលំនៅដ្ឋាន ឬការតម្រង់ទិសនៃសហគមន៍ក្នុងមូលដ្ឋានដោយការវិនិយោគលើកសិរុក្ខកម្មសំខាន់ៗ (ភ្ជាប់ទៅនឹងគោលការណ៍ទី 3, 8, 9)។

## គោលការណ៍ទី 9៖ គាំទ្រសមភាពយេនឌ័រ និងបរិយាប័ន្នសង្គម

បរិយាប័ន្នសង្គម និងសមភាពយេនឌ័រ ត្រូវយកមកពិចារណានៅពេលធ្វើសេចក្តីព្រាងគោលនយោបាយ និងនៅពេលធ្វើផែនការ និងអនុវត្តអន្តរាគមន៍កសិរុក្ខកម្ម។ ចំណុចទាំងអស់នេះគប្បីត្រូវអាចស្វែងរកបានដោយក្រុមតម្រូវការពិសេស ដូចជាក្រុមជួបការលំបាក ដូចជាប្រជាជនភាគតិច និងជនជាតិភាគតិច ក៏ដូចជាយុវជនផងដែរ។
ភាពខុសគ្នាផ្នែកយេនឌ័រ គប្បីត្រូវពិចារណា ហើយការចូលរួមចំណែករួមគ្នាផ្នែកយេនឌ័រ គប្បីត្រូវធ្វើការលើកកម្ពស់នៅក្នុងផ្នែកកសិរុក្ខកម្ម។
ការអនុវត្តគោលការណ៍ណែនាំចំពោះគោលការណ៍នេះ គប្បីមានភាពស្របគ្នាជាមួយនឹងគោលការណ៍ណែនាំអាស៊ានស្តីពីយេនឌ័រ។
គោលការណ៍ណែនាំនេះ រួមបញ្ចូលនូវចំណុចជាអាទិ៍ដូចខាងក្រោម។

**គោលការណ៍ណែនាំ** 9.1. ទទួលស្គាល់នូវសារៈសំខាន់នៃសមភាពយេនឌ័រ និងបរិយាប័

---

8 FAO's Free, *Prior and Informed Consent manual:* https://www.un.org/ development/desa/indigenouspeoples/publications/2016/10/free-prior-and- informed-consent-an-indigenous-peoples- right-and-a-good-practice-for-local- communities-fao/

នូសង្គមនៅក្នុងការធ្វើសេចក្តីសម្រេចចិត្ត ការរៀបចំ និងអនុវត្តអន្តរាគមន៍កសិរុក្ខកម្ម។

**គោលការណ៍ណែនាំ** 9.2. ធានានូវការចូលរួមសំខាន់ៗនៅក្នុងអន្តរាគមន៍កសិរុក្ខកម្មដោយអ្នកកាន់កាប់ដីតូចៗ និងក្រុមជួបការលំបាកក្នុងសង្គម ដូចជាប្រជាជនភាគតិច/ប្រជាជនស៊ីវិល/ក្រុមជនជាតិភាគតិច ប្រជាជនត្រូវបណ្តេញចេញពីលំនៅដ្ឋានជាដើម។

**គោលការណ៍ណែនាំ** 9.3. ធានាថាក្រុមដែលជួបការលំបាកក្នុងសង្គម ទទួលបានអត្ថប្រយោជន៍ពីការវិនិយោគកសិរុក្ខកម្មទ្រង់ទ្រាយធំឬការវិនិយោគពីក្រុមហ៊ុន ឬមិនទទួលរងផលប៉ះពាល់ពីការវិនិយោគនេះនោះទេ (ភ្ជាប់ទៅនឹងគោលការណ៍ទី 8, 10)។

**គោលការណ៍ណែនាំ** 9.4. ធានាថាអន្តរាគមន៍កសិរុក្ខកម្ម ពង្រឹងបន្ថែមនូវសមភាពយេនឌ័រ តាមរយៈការយល់ដឹងពីភាពខុសគ្នានៅក្នុងតួនាទីយេនឌ័រ ការធ្វើសេចក្តីសម្រេចចិត្ត ឧបសគ្គ និងឱកាស និងការស្វែងរកការធ្វើឲ្យប្រសើរឡើងនូវការទទួលបានឱកាសរបស់ស្ត្រីក្នុងផ្នែកកសិរុក្ខកម្ម (រួមបញ្ចូលទាំងព័ត៌មាន បច្ចេកវិទ្យា និងហិរញ្ញវត្ថុ) និងអត្ថប្រយោជន៍ពាក់ព័ន្ធដទៃផ្សេងទៀត។

**គោលការណ៍ណែនាំ** 9.5. ធានាថាជម្រើសកសិរុក្ខកម្ម ឬបច្ចេកវិទ្យាដែលបានណែនាំឲ្យអនុវត្ត មានការគិតពិចារណាអំពីបញ្ហាយេនឌ័រ ជាពិសេសការងារដែលតម្រូវឲ្យមានការចូលរួមពីស្ត្រី។

**គោលការណ៍ណែនាំ** 9.6. ពង្រឹងសមត្ថភាពនៃការស្រាវជ្រាវថ្នាក់ជាតិ និងប្រព័ន្ធផ្សព្វផ្សាយបន្ថែម និងអង្គការក្រៅរដ្ឋាភិបាល ដើម្បីអនុវត្តអន្តរាគមន៍កសិរុក្ខកម្មដែលមានលក្ខណៈបរិយាប័ន្នខាងសង្គម និងយេនឌ័រ (ភ្ជាប់ទៅនឹងគោលការណ៍ទី 2)។

## គោលការណ៍ទី 10៖ ធានាការការពារនិងសិទ្ធិកាន់កាប់ដីធ្លី

**អន្តរាគមន៍កសិរុក្ខកម្ម អាចនឹងបង្កើតនូវភាពតានតឹងក្នុងចំណោមភាគីពាក់ព័ន្ធនៅក្នុងតំបន់មួយចំនួនដែលសិទ្ធិកាន់កាប់ដីធ្លីនិងធនធានធម្មជាតិពុំមានការបែងចែកឲ្យបានច្បាស់លាស់។** ការការពារសិទ្ធិក្នុងការកាប់ដីធ្លី ពិតជាមានសារៈសំខាន់ក្នុងការធានាថា អន្តរាគមន៍កសិរុក្ខកម្មពុំបង្កផលប៉ះពាល់ធ្ងន់ធ្ងរដល់សិទ្ធិសហគមន៍ ឬមានផលប៉ះពាល់ខ្លាំងដល់របនាសម្ព័ន្ធសង្គម និងជីវភាពរស់នៅរបស់សហគមន៍មូលដ្ឋាន។ គោលការណ៍ណែនាំនេះ រួមបញ្ចូលនូវចំណុចជាអាទិ៍ដូចខាងក្រោម។

**គោលការណ៍ណែនាំ** 10.1. យល់ដឹងអំពីសិទ្ធិកាន់កាប់ដីធ្លីរបស់ភាគីពាក់ព័ន្ធនៅក្នុងតំបន់មួយចំនួនដែលមានគោលដៅសម្រាប់អនុវត្តអន្តរាគមន៍កសិរុក្ខកម្មធំៗ ជាពិសេសអន្តរាគមន៍ តាមរយៈការវិនិយោគរបស់ក្រុមហ៊ុន[9]។

**គោលការណ៍ណែនាំ** 10.2. ឲ្យភាគីពាក់ព័ន្ធចូលរួមនៅក្នុងកិច្ចសន្ទនានៅពេលធ្វើផែនការអន្តរាគមន៍កសិរុក្ខកម្មសំខាន់ៗ

---

9 ឧបករណ៍និងសៀវភៅណែនាំ គឺមានសម្រាប់ការវាយតម្លៃសិទ្ធិកាន់កាប់ដី។សូមមើល FAO's Voluntary Guidelines on the Responsible Governance of Tenure of Land, Fisheries and Forests in the Context of National Food Security:http://www.fao.org/docrep/016/ i2801e/i2801e.pdf.

គោរពលើការជំរុញលើកទឹកចិត្ត និងសិទ្ធិនានា និងជានាថាកសិករដែលចូលរួមនៅក្នុងផ្នែកកសិរុក្ខកម្ម ពុំទទួលរងការគំរាមកំហែងឬពុំត្រូវបានបណ្តេញចេញពីផ្ទះសម្បែងដោយបង្ខំ ដោយការវិនិយោគកសិរុក្ខកម្មទ្រង់ទ្រាយធំ (ភ្ជាប់ទៅនឹងគោលការណ៍ទី 3, 7, 8, 9)។

**គោលការណ៍ណែនាំ** 10.3. ធានានូវសុវត្ថិភាពនៃសិទ្ធិកាន់កាប់ដីធ្លីរបស់ភាគីពាក់ព័ន្ធនៅក្នុងផ្នែកកសិរុក្ខកម្ម និង/ឬដីដែលទទួលរងផលប៉ះពាល់ដោយអន្តរាគមន៍កសិរុក្ខកម្ម ដើម្បីជៀសវៀងទំនាស់សង្គម និងធានានូវអត្ថប្រយោជន៍ត្រឡប់មកវិញនៃការវិនិយោគនេះ។

**គោលការណ៍ណែនាំ** 10.4. ធានានូវការយល់ព្រមជាមុន ដោយគ្មានការបង្ខិតបង្ខំ និងដែលមានព័ត៌មានគ្រប់គ្រាន់ពីអ្នកកាន់កាប់សិទ្ធិ ដែលអាចទទួលរងផលប៉ះពាល់ធ្ងន់ធ្ងរពីអន្តរាគមន៍កសិរុក្ខកម្មសំខាន់ៗ និងផ្តល់នូវសំណងសមស្របសម្រាប់ការខូចខាតដែលមានមិនអាចជៀសវាងបាន (ភ្ជាប់ទៅនឹងគោលការណ៍ទី 7, 8)។

## 4.5. គោលការណ៍រៀបចំបច្ចេកទេស

### គោលការណ៍ទី 11៖ រៀបចំជម្រើសកសិរុក្ខកម្មផ្អែកតាមបរិបទ

មានប្រព័ន្ធកសិរុក្ខកម្ម និងជម្រើសជាច្រើនសម្បូរបែប ដែលភាពជោគជ័យនៃប្រព័ន្ធនិងជម្រើសទាំងនោះ គឺអាស្រ័យលើប្រសិទ្ធភាពនៃការរៀបចំនៅក្នុងបរិបទក្នុងមូលដ្ឋានដោយភ្ជាប់ជាមួយនឹងលក្ខខណ្ឌថ្នាក់ក្រោមជាតិ ថ្នាក់ជាតិ និងសាកលលោក។ ការសម្រេចបាននូវអត្ថប្រយោជន៍ខាងសេដ្ឋកិច្ច សង្គមវប្បធម៌ និងបរិស្ថាន គឺជាគោលដៅចាំបាច់ផ្នែកកសិរុក្ខកម្ម។ ជាទូទៅតែងមានតុល្យភាពពាណិជ្ជកម្ម ប៉ុន្តែកសិរុក្ខកម្មដែលមានការរៀបចំបានត្រឹមត្រូវ អាចផ្តល់នូវអត្ថប្រយោជន៍ជាបន្តបន្ទាប់យ៉ាងច្រើន និងបំពេញតាមតម្រូវការខុសៗគ្នារបស់ភាគីពាក់ព័ន្ធ។ ដើម្បីសម្រេចបាននូវអត្ថប្រយោជន៍ជាអតិបរមានៅក្នុងផ្នែកកសិរុក្ខកម្ម គោលការណ៍ណែនាំនេះ រួមបញ្ចូលនូវចំណុចជាអាទិ៍ដូចខាងក្រោម។

**គោលការណ៍ណែនាំ** 11.1. ផ្តល់នូវមធ្យោបាយដែលល្អសម្រាប់អ្នកប្រើប្រាស់ មធ្យោបាយគាំទ្រការធ្វើសេចក្តីសម្រេចចិត្ត ដើម្បីធ្វើការវាយតម្លៃព័ត៌មានជារួម កំណត់ឱកាស និងឧបសគ្គ និងធ្វើការជ្រើសរើសជម្រើសនានាដែលមានព័ត៌មានគ្រប់គ្រាន់អំពីជម្រើសកសិរុក្ខកម្ម។ ការគាំទ្រសេចក្តីសម្រេច រួមបញ្ចូលនូវព័ត៌មាននិងទិន្នន័យនៃការវាស់វែងផ្នែកជីវៈរូបសាស្ត្រ (ដូចជាការបង្កើតផែនទី ការប្រើប្រាស់ដីប្រភេទដី សីតុណ្ហភាព និងកម្រិតទឹកភ្លៀង) ស្ថិតិសង្គមសេដ្ឋកិច្ច រួមមានយែនឌ័រ ព័ត៌មានទីផ្សារ បញ្ហាហេដ្ឋារចនាសម្ព័ន្ធ និងគោលនយោបាយពាក់ព័ន្ធនានា។

**គោលការណ៍ណែនាំ** 11.2. ធានាថាជម្រើសកសិរុក្ខកម្ម ត្រូវបានជ្រើសរើសដោយផ្អែកលើតម្រូវការជាក់លាក់ ផលប្រយោជន៍ ឬគោលបំណងរបស់បុគ្គល (អ្នកកាន់កាប់ដីតូចៗ អ្នកកាន់កាប់ដីធំៗ ក្រុមហ៊ុន) និងវិស័យសាធារណៈ (រដ្ឋាភិបាល អង្គការមិនមែនរដ្ឋាភិបាល) និងភាគីពាក់ព័ន្ធនានា ដោយធ្វើការគិតពិ

ចារណាអំពីការផ្លាស់ប្តូរមួយចំនួននៅក្នុងរបបអាកាសធាតុនាពេលអនាគត ស្ថានភាពសេដ្ឋកិច្ច និងគោលនយោបាយ (ភ្ជាប់ទៅនឹងគោលការណ៍ទី 3, 7, 8, 9)។

**គោលការណ៍ណែនាំ** 11.3. រៀបចំជម្រើសកសិរុក្ខកម្មផ្អែកលើបរិបទក្នុងមូលដ្ឋានដែលមានទំនាក់ទំនងជាមួយលក្ខខណ្ឌជីវរូបសាស្ត្រ សង្គមសេដ្ឋកិច្ច (រួមមានការងារដែលមាន និងផលចំណេញ) លក្ខខណ្ឌវប្បធម៌ ហេដ្ឋារចនាសម្ព័ន្ធ ទីផ្សារនិងគោលនយោបាយ (ភ្ជាប់ទៅនឹងគោលការណ៍ណែនាំទី 12.2 និងគោលការណ៍ 3, 5, 9, 10) និងការគិតពិចារណាអំពីពេលវេលា (ឧទាហរណ៍ ការផ្លាស់ប្រភេទរុក្ខជាតិ ដំណាំ សត្វចិញ្ចឹម ត្រី) និងទំហំផ្ទៃទំនេរ (ឧទាហរណ៍ ការរៀបចំលំហនៃសមាសធាតុប្រព័ន្ធ) ទិដ្ឋភាពផ្សេងៗផ្នែកកសិរុក្ខកម្ម។

**គោលការណ៍ណែនាំ** 11.4. មានគោលបំណងសម្រាប់អត្ថប្រយោជន៍ជាច្រើន ដោយជានាថាជម្រើសកសិរុក្ខកម្មត្រូវបានរៀបចំឡើងដើម្បីផ្តល់នូវអត្ថប្រយោជន៍សេដ្ឋកិច្ចជាបន្តបន្ទាប់ ជាមួយនឹងអត្ថប្រយោជន៍សង្គមវប្បធម៌ និងបរិស្ថាន ដោយគិតពិចារណាអំពីបរិបទក្នុងមូលដ្ឋាន រួមទាំង លក្ខខណ្ឌសង្គមវប្បធម៌ (ភ្ជាប់ទៅនឹងគោលការណ៍ទី 2, 9) និង ស្ថានភាពកាន់កាប់ដីធ្លីនៃភាគីពាក់ព័ន្ធដោយផ្ទាល់ (ភ្ជាប់ទៅនឹងគោលការណ៍ទី 10)។

**គោលការណ៍ណែនាំ** 11.5. ធានាថាជម្រើសកសិរុក្ខកម្មដែលបានជ្រើសរើសរួច ត្រូវបានអនុវត្តនៅក្នុងការរួមផ្សំបញ្ចូលគ្នាជាមួយការអភិរក្សដែលមានជាធរមាន និងបច្ចេកវិទ្យាកសិកម្មឆ្លាតវៃផ្នែកអាកាសធាតុ[10] ដូចជា ការភ្ជួរតាមរយៈកម្ពស់ (ជាពិសេសនៅលើដីជ្រលងចោទៗ) ការដាំដំណាំគម្រប ការគ្របដី ការកាប់ចង្អុរ ការមិនភ្ជួររាស់ដី ភាពខុសៗគ្នានៃភាពធន់ទ្រាំទៅនឹងការរាំងស្ងួត និងបច្ចេកវិទ្យាសន្សំសំចៃទឹក។

**គោលការណ៍ណែនាំ** 11.6. ផ្តល់នូវគោលការណ៍ណែនាំបច្ចេកទេសដើម្បីជានានូវការគ្រប់គ្រងត្រឹមត្រូវនៃជម្រើសកសិរុក្ខកម្មដែលបានជ្រើសរើសរួច តាមរយៈការបណ្តុះបណ្តាលនិងសម្ភារៈពង្រីក ការផ្សព្វផ្សាយបន្ថែមដើម្បីគាំទ្រដល់ការអប់រំជាបន្តបន្ទាប់និងការសិក្សាពេញមួយជីវិត (ភ្ជាប់ទៅនឹងគោលការណ៍ទី 2, 6)។

## គោលការណ៍ទី 12៖ ជ្រើសរើសសមាសធាតុកសិរុក្ខកម្មតាមបែបចូលរួម

ការជ្រើសរើសនិងការសម្រេចចិត្តចំពោះរុក្ខជាតិ ដំណាំ សត្វចិញ្ចឹម និងត្រី/សមាសធាតុវារីជាតិ ពាក់ព័ន្ធនឹងទិដ្ឋភាពកាលាកាសនៃកសិរុក្ខកម្ម គឺជាការចាំបាច់បំផុតដើម្បីទទួលបានជោគជ័យ។ អាស្រ័យលើគោលដៅនានា (រយៈពេលខ្លី មធ្យម និងរយៈពេលវែង) នៃម្ចាស់ដីខ្នាតតូច ខ្នាតធំ ក្រុមកសិករ ធនធានផលិតកម្មរបស់ពួកគេ (ទំហំដី

10 សូមមើលសេចក្តីណែនាំតំបន់អាស៊ានសម្រាប់ការលើកកម្ពស់ការអនុវត្តកសិកម្មឆ្លាតវៃខាងអាកាសធាតុសម្រាប់ជាឧទាហរណ៍និងគ្រោងការសម្រាប់កិច្ចសហប្រតិបត្តិការ៖http://www.asean.org/wp-content/uploads/images/2015/October/ ASEAN-Regional-Guidelines-on-Promoting-CSA-Practices/ASEAN%20Regional%20Guidelines%20on%20Promoting%20CSA%20Practices-endorsed%2037th%20 AMAF.pdf

ពលកម្ម និងមូលធន) និងការគិតពិចារណាដទៃផ្សេងទៀត ដូចជាការកាន់កាប់ដីធ្លី និងទីផ្សារ នោះការជ្រើសរើសសមាសធាតុកសិរុក្ខកម្ម គប្បីត្រូវធ្វើឡើងផ្អែកលើគោលគំនិត៖ "ប្រភេទរុក្ខជាតិ ដំណាំ សត្វ និង/ឬ ត្រីដែលត្រឹមត្រូវនិងសមស្របទៅនឹងទីកន្លែង និងគោលបំណង"។ គោលការណ៍ណែនាំនេះ រួមបញ្ចូលនូវចំណុចជាអាទិ៍ដូចខាងក្រោម។

**គោលការណ៍ណែនាំ** 12.1. កំណត់ពីរុក្ខជាតិ សត្វ និង/ឬប្រភេទសត្វក្នុងទឹក និងប្រភេទផ្សេងៗដែលស៊ីគ្នាទៅនឹងលក្ខខណ្ឌជីវរូបសាស្ត្រ (សីតុណ្ហភាព កម្រិតទឹកភ្លៀង រយៈកម្ពស់ និងដី) នៃតំបន់ដែលមានគោលដៅសម្រាប់ការអនុវត្តកសិរុក្ខកម្មដោយធ្វើការកត់សម្គាល់ពីវត្តមាននៃភាវៈទាំងនោះនៅក្នុងតំបន់ និងទីកន្លែងស្រដៀងគ្នា (ភ្ជាប់ទៅនឹងគោលការណ៍ទី11)[11]។ គិតពិចារណាអំពីការផ្លាស់ប្តូរនានាក្នុងពេលអនាគត របបអាកាសធាតុ នៅពេលជ្រើសរើសពូជ ប្រភេទ និងជម្រើសពូជ រួមបញ្ចូលនូវប្រព័ន្ធកសិរុក្ខកម្មផងដែរ។ វាពិតជាមានសារៈសំខាន់ក្នុងការអនុវត្តតាមដំណើរការនេះ ដោយមានការធ្វើការអង្កេតផ្អែកទីផ្សារនៃប្រភេទនិងនានាភាពដើម្បីធ្វើការកំណត់ទីផ្សារនិងយុទ្ធសាស្ត្រនានាសម្រាប់ការធ្វើទីផ្សារផលិតផលកសិរុក្ខកម្ម (ភ្ជាប់ទៅនឹងគោលការណ៍ទី 11)។

11 ព័ត៌មានអនឡាញ និងមូលដ្ឋានទិន្នន័យនៃប្រភេទនានាដែលសមស្របទៅនឹងលក្ខខណ្ឌជីវរូបសាស្ត្រក្នុងមូលដ្ឋាន និងចំណង់ចំណូលចិត្តរបស់ភាគីពាក់ព័ន្ធ អាចចូលទៅមើលបានសម្រាប់ជម្រើសដែលមានការកើនឡើង។ ឧទាហរណ៍៖ មូលដ្ឋានទិន្នន័យផ្អែកមុខងារអេកូឡូស៊ី (http://www.worldagroforestry. org/output/tree-functional-and-ecological-databases).

**គោលការណ៍ណែនាំ** 12.2. ធ្វើការអង្កេត ឬរៀបចំសិក្ខាសាលាជាមួយភាគីពាក់ព័ន្ធនៅក្នុងស្រុកដើម្បីកំណត់ពីការប្រើប្រាស់តាមការចង់បាន (ចំណីអាហារ និងសេវាកម្ម) នៃរុក្ខជាតិ ដំណាំ សត្វ ត្រី និងពូជជាក់លាក់ ដែលពួកគេចង់ដាំដុះនិងចិញ្ចឹម ដោយធានាថាការធ្វើដំណើរការមានសមភាពនិងបរិប័ន្ន។ នៅពេលចាំបាច់ត្រូវរៀបចំការស្ទង់មតិដាច់ដោយឡែកសម្រាប់ក្រុមមនុស្សប្រុស ស្ត្រី យុវជន និងក្រុមជួបការលំបាក ដើម្បីធានាថាអ្នកទាំងនោះ អាចផ្តល់នូវការរួមចំណែកបាន (ភ្ជាប់ទៅនឹងគោលការណ៍ទី 8, 9, 10 11)។

**គោលការណ៍ណែនាំ** 12.3. ត្រួតពិនិត្យនិងអនុវត្តនូវគោលការណ៍ណែនាំបច្ចេកទេសដែលមានស្រាប់ ដែលអនុម័តដោយរដ្ឋជាសមាជិកអាស៊ានពាក់ព័ន្ធនឹងការជ្រើសរើស គុណភាព ប្រភព និងការចែកចាយ និងការគ្រប់គ្រងជីវករ ក៏ដូចជាការជ្រើសរើសសត្វចិញ្ចឹមនិងប្រភេទវារីជាតិ និងសត្វទឹកបង្កាត់បានត្រឹមត្រូវ។ ធានាថាពូជក្នុងស្រុក សត្វចិញ្ចឹម និងពពួកវារីជាតិ និង/ឬពូជបង្កាត់ ពុំមានផលប៉ះពាល់ធ្ងន់ធ្ងរដោយប្រភេទពូជនិង/ឬពូជបង្កាត់នៅក្នុងប្រព័ន្ធកសិរុក្ខកម្ម។

**គោលការណ៍ណែនាំ** 12.4. ធានាថាមានការចូលរួមយ៉ាងសកម្មពីភាគីពាក់ព័ន្ធសំខាន់ៗ ជាពិសេសកសិករ វិនិយោគិន កម្មករ និងភ្នាក់ងាររដ្ឋាភិបាល នៅក្នុងការធ្វើសេចក្តីសម្រេចចិត្តពាក់ព័ន្ធនឹងសមាសធាតុនៅក្នុងប្រព័ន្ធកសិរុក្ខកម្ម។

# 4.6. គោលការណ៍ ទំនាក់ទំនង និង មាត្រដ្ឋាន

## គោលការណ៍ទី 13៖ ផ្សព្វផ្សាយពីចំណេះដឹងកសិរុក្ខកម្មប្រកបដោយប្រសិទ្ធភាព

ត្រូវគិតពិចារណាលើកង្វះខាតចំណេះដឹងទូទៅអំពីការអភិវឌ្ឍនិងការគ្រប់គ្រងកសិរុក្ខកម្មក្នុងចំណោមរដ្ឋជាសមាជិកអាស៊ាន និងលក្ខណៈស្មុគ្រស្មាញនិងភាពខុសគ្នានៃការអនុវត្តកសិរុក្ខកម្ម ការគ្រប់គ្រងចំណេះដឹង និងការបង្ហាញវា គឺពិតជាមានសារៈសំខាន់សម្រាប់អ្នកបង្កើតគោលនយោបាយ កសិករ វិនិយោគិន និងអ្នកដើរតួរក្នុងទីផ្សារ ដើម្បីធ្វើការលើកទឹកចិត្តឲ្យមានការអនុវត្តយកឲ្យបានទូលំទូលាយ និងការអភិវឌ្ឍជាបន្តបន្ទាប់ផ្នែកកសិរុក្ខកម្ម។ គោលការណ៍ណែនាំនេះ រួមបញ្ចូលនូវចំណុចជាអាទិ៍ដូចខាងក្រោម។

**គោលការណ៍ណែនាំ** 13.1.
កំណត់ចំណេះដឹង និងតម្រូវការនៃការទំនាក់ទំនង និងចន្លោះប្រហោងនៃភាគីពាក់ព័ន្ធទាំងអស់ – រួមមានកសិករ ភ្នាក់ងារផ្សព្វផ្សាយបន្ថែម និងប្រឹក្សាយោបល់នៅក្នុងស្រុក និងរដ្ឋាភិបាលថ្នាក់ជាតិ អ្នកដើរតួទីផ្សារ វិនិយោគិន – តាមរយៈវិធីសាស្ត្រចូលរួម ដើម្បីផ្តល់នូវការគាំទ្រដែលសមស្របទៅតាមការចង់បាន។

**គោលការណ៍ណែនាំ** 13.2 បង្ហាញវាឲ្យបានច្បាស់នៅក្នុងចំណោមភាគីពាក់ព័ន្ធទាំងអស់នៅក្នុងតំបន់ទេសភាព និង/ឬខ្សែចង្វាក់តម្លៃជាភាសានិងទម្រង់ដែលចង់បាន – រួមមានជាអាទិ៍ ឯកសារជាលាយលក្ខណ៍អក្សរ ជាសំឡេង ជារូបភាព នៅក្នុងកិច្ចប្រជុំធំនិងតូច សិក្ខាសាលាជំនាញ ការបណ្តុះបណ្តាលនៅតាមស្រែគំរូ និងដីបង្ហាញ – ដើម្បីឲ្យមានការយល់ដឹងបានល្អប្រសើរអំពីបញ្ហាប្រឈមនានានៅពេលប្រឈមនឹងការជ្រើសយកកសិរុក្ខកម្ម។

**គោលការណ៍ណែនាំ** 13.3.
ការពង្រឹងការគ្រប់គ្រងចំណេះដឹង និងការបង្ហាញពីសមត្ថភាពស្ថាប័នទទួលបន្ទុក និងស្ថាប័ននានាដែលពាក់ព័ន្ធនឹងកសិរុក្ខកម្ម រួមមានដៃគូរបស់ស្ថាប័នទាំងនេះនៅកម្រិតថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ ដើម្បីធ្វើការបង្កើតឡើងដោយប្រសិទ្ធភាពនូវការចែករំលែកចំណេះដឹង និងជំនាញ ផ្តល់នូវគោលការណ៍ណែនាំបច្ចេកទេស សម្របសម្រួលការធ្វើផែនការនិងសេចក្តីសម្រេចនៅកម្រិតខុសៗគ្នាគ្រប់គ្រងតាមដានលទ្ធផលនិងផលប៉ះពាល់ និងលើកកម្ពស់វិធីសាស្ត្រ លទ្ធផល និងសមិទ្ធផល ជាពិសេសការគាំទ្រយ៉ាងទូលំទូលាយដល់ការកៀងគរហិរញ្ញវត្ថុសម្រាប់ការស្រាវជ្រាវនិងការអភិវឌ្ឍកសិរុក្ខកម្ម។

**គោលការណ៍ណែនាំ** 13.4. ផ្តល់នូវការគ្រប់គ្រងនិងការបង្ហាញអំពីចំណេះដឹង ដើម្បីធានាថាភាគីពាក់ព័ន្ធទាំងអស់ទទួលបានការជូនដំណឹង និងអាចចូលរួមនៅក្នុងកិច្ចពិភាក្សា គឺអាចបង្កើនចំណេះដឹងនិងជំនាញ និងអាចសម្របសម្រួលនិងកែលម្អបានជាបន្តបន្ទាប់។

## គោលការណ៍ទី 14៖ ការធ្វើផែនការសម្រាប់មាត្រដ្ឋាន និងនិរន្តរភាព

តាមរយៈការគិតពិចារណាអំពីបរិបទជាក់លាក់នៃអន្តរាគមន៍កសិរុក្ខកម្ម ការកំណត់ទំហំកសិរុក្ខកម្ម

ត្រូវធ្វើផែនការដោយប្រុងប្រយ័ត្ន និងត្រូវគិតពិចារណាអំពីទស្សនៈជាសាកលនិងទស្សនៈតាមបរិបទ។ លក្ខខណ្ឌតម្រូវនៃការកំណត់មាត្រដ្ឋានកសិរុក្ខកម្មដើម្បីសម្រេចបាននូវប្រសិទ្ធភាពរយៈពេលយូរ ត្រូវធ្វើការកំណត់ដោយប្រុងប្រយ័ត្នបំផុត។ គោលការណ៍ណែនាំនេះ រួមបញ្ចូលនូវចំណុចជាអាទិ៍ដូចខាងក្រោម។

**គោលការណ៍ណែនាំ** 14.1. ឲ្យភាគីពាក់ព័ន្ធនិងអ្នកមកពីវិស័យផ្សេងៗចូលរួមនៅក្នុងការធ្វើផែនការសម្រាប់ការកំណត់ទំហំអន្តរាគមន៍កសិរុក្ខកម្ម (ភ្ជាប់ទៅនឹងគោលការណ៍ទី 3)។

**គោលការណ៍ណែនាំ** 14.2. យល់ដឹងពីសក្តានុពលខ្ពស់បំផុតសម្រាប់ការកំណត់និងការកម្រិតទំហំកសិរុក្ខកម្ម ដោយធ្វើការត្រួតពិនិត្យឱកាសពីខាងក្នុងនិងខាងក្រៅ រួមទាំងលក្ខខណ្ឌជីវរូបសាស្ត្រ សង្គម វប្បធម៌ ការងារ និងទីផ្សារ ក៏ដូចជាយុទ្ធសាស្ត្រនិងផែនការនៃវិស័យដែលពាក់ព័ន្ធ ដែលអាចជះឥទ្ធិពលដល់ការកំណត់ទំហំ ដែលបានស្នើឡើង។

**គោលការណ៍ណែនាំ** 14.3. ធានាថាលក្ខខណ្ឌតម្រូវនានាសម្រាប់ការកំណត់មាត្រដ្ឋាន មានការយល់ដឹងដោយភាគីពាក់ព័ន្ធនិងត្រូវបានយកមកដោះស្រាយទាំងស្រុងឬដោយផ្តែកទីតាំងគោលដៅ។

**គោលការណ៍ណែនាំ** 14.4. ការយល់ដឹងអំពីការកំណត់ទំហំ ដែលអាចមានលក្ខណៈជាទិដ្ឋភាពច្វេកទេសនិងស្ថាប័នផ្តែកកសិរុក្ខកម្ម ឬគិតលើទិដ្ឋភាពទាំងពីរ។ ទិដ្ឋភាពបច្ចេកទេស រួមមានការជ្រើសរើសរុក្ខជាតិ ដំណាំ សត្វចិញ្ចឹម និង/ឬប្រភេទវារីជាតិនៃសមាសធាតុប្រព័ន្ធ ការអនុវត្តការរៀបចំនិងការគ្រប់គ្រងពូជ និងផលប៉ះពាល់លើកម្រិតកសិដ្ឋាននិងតំបន់ទេសភាពរំពឹងទុក ដែលប៉ះពាល់ដល់ទិដ្ឋភាពស្ថាប័ន រួមមានការរៀបចំម្ចាស់ដីតូចៗ ការបង្កើតភាពជាដៃគូ វិធីសាស្រ្តបណ្តុះបណ្តាល និងយន្តការហិរញ្ញប្បទាន។

**គោលការណ៍ណែនាំ** 14.5. យល់ព្រមចំពោះម៉ូឌុលដែលសមស្របសម្រាប់ការកំណត់ទំហំបរិបទជាក់លាក់ រួមមានអ្នកដើរតួសំខាន់ៗដែលពាក់ព័ន្ធ ដូចជារដ្ឋាភិបាលក្នុងស្រុក ក្រុមហ៊ុនឯកជន ក្រុមផលិត ទីភ្នាក់ងារផ្សព្វផ្សាយបន្ត។

**គោលការណ៍ណែនាំ** 14.6. ត្រួតពិនិត្យវិធីសាស្ត្រកំណត់មាត្រដ្ឋាន ដំណើរការ និងសមិទ្ធផលតាមពេលវេលាដើម្បីដោះស្រាយចន្លោះប្រហោង បញ្ហា និងឱកាសនានា ឬធ្វើការផ្លាស់ប្តូរវិធានការមួយចំនួន។

# ជំពូក 5
# ការគិតពិចារណាអំពីការអនុវត្ត

គោលការណ៍ និងគោលការណ៍ណែនាំទាំងនេះបង្កើតបានជាក្របខណ្ឌមួយដែលអាចសម្របសម្រួលដល់ការពិភាក្សាអំពីការបង្កើតគោលនយោបាយ យុទ្ធសាស្ត្រ កម្មវិធី និងគម្រោងកសិរុក្ខកម្មដោយរដ្ឋជាសមាជិកអាស៊ាន។ ពួកគេក៏ផ្តល់នូវគោលការណ៍ណែនាំសម្រាប់ការវិនិយោគកសិរុក្ខកម្មដោយវិស័យឯកជនផងដែរ។ សម្រាប់គោលបំណងនៃការអនុវត្ត គោលការណ៍ណែនាំបច្ចេកទេសដែលពាក់ព័ន្ធនឹងកសិរុក្ខកម្មដែលបង្កើតឡើងទៅតាមតំបន់អេកូឡូស៊ី និងសង្គមវប្បធម៌ជាក់លាក់នៅក្នុងតំបន់អាស៊ាន គប្បីត្រូវអនុវត្តតាម។
ការគិតពិចារណាមួយចំនួនសម្រាប់ការអនុវត្តនេះ ត្រូវបានពិភាក្សាដូចខាងក្រោម។

## 5.1. តួនាទីស្ថាប័ន និងការរៀបចំ

រដ្ឋាភិបាលនិងទីភ្នាក់ងារនៅកម្រិតខុសៗគ្នានៃរដ្ឋជាសមាជិកអាស៊ាន
អង្គការមិនមែនរដ្ឋាភិបាល សមាគមកសិករ និងសហករ អង្គការនៅតាមសហគមន៍ វិស័យឯកជន (ម្ចាស់ដីខ្នាតតូចឬធំ សហគ្រាសខ្នាតតូចនិងមធ្យម) និងផ្នែកដទៃផ្សេងទៀត មាន តួនាទីខុសៗគ្នាក្នុងការអនុវត្តគោលការណ៍នេះ។
កិច្ចខិតខំប្រឹងប្រែងរួមគ្នា ត្រូវការជាចាំដើម្បីបង្កើតបរិស្ថានអនុគ្រោះមួយដែលលើកកម្ពស់សមត្ថភាពស្ថាប័ន និងកិច្ចសហប្រតិបត្តិការ និងការធ្វើសេចក្ដីសម្រេចចិត្ត
តាមបែបចូលរួម (គោលការណ៍ 1, 2, 3)។
ការកំណត់ពីភាគីពាក់ព័ន្ធសំខាន់ៗ
និងការយល់ដឹងពីតួនាទី តម្រូវការ
និងកត្តាជំរុញចិត្ត គឺជារឿងចាំបាច់ឆ្ពោះទៅរកការបង្កើតបរិស្ថានអនុគ្រោះផ្នែកកសិរុក្ខកម្ម។
អន្តរាគមន៍ជោគជ័យផ្នែកកសិរុក្ខកម្ម តម្រូវឲ្យមានការគាំទ្រពីរដ្ឋាភិបាលផ្នែកគោលនយោបាយ និងកម្មវិធីហិរញ្ញប្បទាន ដោយផ្តល់អត្ថប្រយោជន៍ដែលមានលក្ខណៈប្រកួតប្រជែងពីផលិតកម្មកសិកម្មឯករប្បកម្មតាមបែបពាណិជ្ជកម្ម។ ដូចបានរៀបរាប់យ៉ាងច្រើននៅក្នុងគោលការណ៍ទី 1 រដ្ឋជាសមាជិកអាស៊ាន គប្បីកំណត់ពីស្ថាប័នទទួលខុសត្រូវសម្រាប់ការអភិវឌ្ឍកសិរុក្ខកម្មនៅក្នុងប្រទេសរៀងៗខ្លួន។
កម្មវិធីព្រៃឈើសហគមន៍ គឺជាកម្មវិធីមួយក្នុងចំណោមកម្មវិធីថ្នាក់ជាតិជាច្រើន និងយន្តការដែលអនុញ្ញាតឲ្យមានការអនុវត្តកសិរុក្ខកម្មបាន
ដោយមានការគាំទ្រផ្នែកគោលនយោបាយ និងហិរញ្ញវត្ថុ។
រដ្ឋជាសមាជិកអាស៊ានមួយចំនួន
មានកម្មវិធីព្រៃឈើសហគមន៍
ដែលមានផែនការ និងគោលដៅដើម្បីលើកកម្ពស់ជីវភាពរស់នៅរបស់ប្រជាជន ហើយស្របពេលជាមួយគ្នានោះបានការពារនិងគ្រប់គ្រងព្រៃឈើប្រកបដោយចីរភាព។ កសិរុក្ខកម្ម បានដើរតួនាទីយ៉ាងសំខាន់នៅក្នុងការសម្រេចគោលដៅទាំងអស់នេះ។ វិនិយោគិនវិស័យឯកជនបានដើរតួនាទីយ៉ាងសំខាន់នៅក្នុងការអភិវឌ្ឍ

កសិរុក្ខកម្មជាពិសេស ក្រុមហ៊ុនកសិឧស្សាហកម្មដែលមានផលប្រយោជន៍នៅក្នុងផលិតកម្ម

ប្រកបដោយនិរន្តរភាពដែលមានគោលបំណងចង់បានវិញ្ញាបនបត្របញ្ជាក់ដែលនឹងអាចឲ្យពួកគេបង្កើតម៉ាកយីហោផលិតផលថាជាផលិតផលដែល "មិនប៉ះពាល់ដល់បរិស្ថាន"។

ការស្រាវជ្រាវថ្នាក់ជាតិនិងស្ថាប័នសិក្សាធិការត្រូវការឲ្យមានការចូលរួមនៅក្នុងការស្រាវជ្រាវ ការបណ្តុះបណ្តាល និងការអប់រំផ្នែកកសិរុក្ខកម្មដើម្បី 1)បង្កើតចំណេះដឹងកសិរុក្ខកម្មជាបន្តបន្ទាប់ និងភស្តុតាងនានាដែលត្រូវការសម្រាប់ការកែសម្រួល និង/ឬការសម្រិតសម្រាំងអនុសាសន៍បច្ចេកទេស និងគោលនយោបាយ 2)បង្កើតមធ្យោបាយនិងវិធីសាស្ត្រសម្រាប់ការបង្កើតចំណេះដឹង ការគ្រប់គ្រងនិងការវាយតម្លៃផលប៉ះពាល់ និង 3) ការគាំទ្រដល់ការសិក្សារៀនសូត្រ ការអប់រំ និងការចែករំលែកចំណេះដឹងជាបន្តបន្ទាប់។ ការសិក្សាស្រាវជ្រាវមូលដ្ឋាននិងការស្រាវស្រាវអនុវត្តន៍នៅក្នុងផ្នែកកសិរុក្ខកម្ម គប្បីត្រូវអនុវត្តតាមរបៀបនៃការចូលរួម (គោលការណ៍ 3, 8, 9)។

សេវាផ្សព្វផ្សាយផ្នែកព្រៃឈើ និងកសិកម្ម ឬសេវាប្រឹក្សាយោបល់នៅតាមទីជនបទនៅក្នុងរដ្ឋជាសមាជិកអាស៊ាន ក៏បានដើរតួនាទីយ៉ាងសំខាន់នៅក្នុងការចែករំលែកចំណេះដឹងនិងបទពិសោធន៍ផងដែរ ការបណ្តុះបណ្តាល និងការកសាងក្រុមកម្មករជាមួយនឹងជំនាញត្រឹមត្រូវដើម្បីសម្របសម្រួលដល់ការធ្វើផែនការ ការអនុវត្ត ការគ្រប់គ្រងតាមដាន និងការវាយតម្លៃកសិរុក្ខកម្ម។

សមាគមន៍កសិករនិងសហករ និងអង្គការនៅតាមមូលដ្ឋាន ក៏មានតួនាទីសំខាន់នៅក្នុងបង្កើតរួមគ្នានូវចំណេះដឹងកសិរុក្ខកម្ម ការចែករំលែកចំណេះដឹងនិងបទពិសោធន៍ពីកសិករមួយទៅកសិករមួយ តាមរយៈការជ្រើសរើសជម្រើសកសិរុក្ខកម្មដែលល្អបំផុតសម្រាប់បរិបទផ្ទាល់ខ្លួនដែលពាក់ព័ន្ធនឹង លក្ខខណ្ឌជីវរូបសាស្ត្រ សង្គមសេដ្ឋកិច្ច វប្បធម៌ ទីផ្សារ និងគោលនយោបាយនៃការជំរុញលើកទឹកចិត្ត ក្តីបារម្ភ និងផលិតផលកសិករ និងការជំរុញកិច្ចសន្ទនាក្នុងចំណោមភាគីពាក់ព័ន្ធរួមទាំងអ្នកបង្កើតគោលនយោបាយ និងវិនិយោគិនផងដែរ។

សមាជិក CGIAR ដែលជាកម្មវិធីភាពជាដៃគូសាកលសម្រាប់អនាគតសន្តិសុខស្បៀង ក៏បានដើរតួនាទីយ៉ាងសំខាន់ផងដែរ ដោយរៀបចំកម្មវិធីស្រាវជ្រាវរបស់ពួកគេឲ្យស្របជាមួយនឹងរបៀបវារៈកសិរុក្ខកម្មនៃរដ្ឋជាសមាជិកអាស៊ាន និង/ឬការធ្វើការស្រាវដោយផ្ទាល់ជាមួយនឹងដៃគូក្នុងតំបន់និងដៃគូជាតិ។

ជាចុងក្រោយ អង្គការនានារបស់អង្គការសហប្រជាជាតិ ជាពិសេស FAO បានដើរតួនាទីយ៉ាងសំខាន់ក្នុងការផ្តល់នូវជំនួយបច្ចេកទេស យោបផ្នែកគោលនយោបាយ នៅត្រង់ចំណុចណាដែលអាចអនុវត្តបាន ដោយបានផ្តល់មូលនិធិសម្រាប់ការអនុវត្តគោលការណ៍ណែនាំទាំងអស់នេះ។

## 5.2. ការធ្វើផែនការ និងការផ្តល់ ហិរញ្ញប្បទាន

ដោយសារកសិរុក្ខកម្ម ពុំមែនស្ថិតនៅក្រោមការគ្រប់គ្រងដោយផ្ទាល់រវាងផ្នែកកសិកម្ម និងរុក្ខាប្រម៉ាញ់ រដ្ឋជាសមាជិកអាស៊ាន ទទួលបានការលើកទឹកចិត្តឲ្យបង្កើតកម្មវិធីកសិរុក្ខកម្មជាតិ ដោយដំបូងត្រូវពិតពិចារណាលើហេដ្ឋារចនាសម្ព័ន្ធស្ថាប័នដែលត្រូវមានជាចាំបាច់ដើម្បីធ្វើឲ្យកម្មវិធីជាតិសម្រេចជោគជ័យបាន (គោលការណ៍ 1)។ ក្រោមការដឹកនាំដោយស្ថាប័នដែលកំណត់រួចនៅក្នុងក្រសួងពាក់ព័ន្ធ គណៈកម្មការពហុវិស័យពិសេស ឬក្រុមការងារមួយ គប្បីត្រូវបង្កើតឡើងដើម្បីសម្របសម្រួលដល់ការធ្វើផែនការ។ វិធីសាស្ត្រនេះ ត្រូវស្របគ្នាជាមួយក្របខណ្ឌពហុវិស័យអាស៊ានស្តីពីការប្រែ

ប្រែប្រួលអាកាសធាតុ៖ កសិកម្ម ជលផល និងរុក្ខា
ប្រម៉ាញ់ឆ្ពោះទៅរកសន្តិសុខស្បៀង ដែលផ្តល់
នូវយន្តការមួយសម្រាប់សកម្មភាពដែលមាន
ការសម្របសម្រួល។

ការធ្វើផែនការសម្រាប់ចក្ខុវិស័យកសិរុក្ខកម្មនិ
ងផែនទីបង្ហាញផ្លូវដោយរដ្ឋជាសមាជិកអា
ស៊ាន គឺពិតជាមានភាពចាំបាច់ក្នុងការបង្ហាញ
ផ្លូវឆ្ពោះទៅមុខ។
មានវិធីជាច្រើនដែលជំរុញដល់ការអភិវឌ្ឍកសិរុ
ក្ខកម្មនៅក្នុងតំបន់ រួមទាំងការបង្កើតបរិស្ថានវិ
និយោគអនុគ្រោះដោយមានគោលនយោបាយ
គាំទ្រដែលជំរុញការបើកបង្កើតទីផ្សារសម្រាប់ផ
លិតផលកសិរុក្ខកម្ម និងការបញ្ជ្រាបកសិរុក្ខក
ម្មនៅក្នុងយុទ្ធសាស្ត្រ ផែនការ
និងគោលដៅដែលមានស្រាប់ ឧទាហរណ៍ផែន
ការអភិវឌ្ឍន៍ប្រកបដោយចីរភាព ឬផែនការអភិ
វឌ្ឍន៍បញ្ចេញជាតិពុលទាប, REDD+
ផែនការសកម្មភាពថ្នាក់ជាតិ,
ផែនការអភិវឌ្ឍន៍ជនបទ
កម្មវិធីស្តារគុណភាពដី
ការធ្វើផែនការប្រើប្រាស់ដី ការចូលរួមចំណែក
ដើម្បីអនុវត្តអនុសញ្ញាក្របខណ្ឌសហប្រជាជា
តិស្តីពីការប្រែប្រួលអាកាសធាតុ។
ដៃគូអភិវឌ្ឍន៍អន្តរជាតិ និងដៃគូទ្វេភាគីនៃរដ្ឋជា
សមាជិកអាស៊ាន
អាចស្វែងរកបានដើម្បីធ្វើឲ្យកម្មវិធីអភិវឌ្ឍន៍រប
ស់ពួកគេមានភាពស្របគ្នា
ឬផ្តល់ការគាំទ្រមូលនិធិដោយផ្ទាល់ ជូនដល់ក
ម្មវិធីកសិរុក្ខកម្មរបស់រដ្ឋជាសមាជិក។

ការធ្វើផែនការសម្រាប់កម្មវិធីកសិរុក្ខកម្ម
ឬគម្រោងនានានៅកម្រិតថ្នាក់ជាតិ
និងកម្រិតថ្នាក់ក្រោមជាតិ តម្រូវឲ្យមានការវិភា
គលើវិសាលភាពនិងស្ថានភាពនានាដើម្បីកំ
ណត់ពីបញ្ហា បញ្ហាប្រឈម ចន្លោះប្រហោង
និងឱកាសនានា។ ប្រសិនបើមានសញ្ញាវិជ្ជមា
នសម្រាប់វិនិយោគិនធំៗ (ម្ចាស់ដីតូចៗ
ម្ចាស់ដីធំៗ និងក្រុមហ៊ុន) ទំនុកចិត្តក្នុងការវិនិ
យោគលើកសិរុក្ខកម្ម
ការសិក្សាសមិទ្ធិលទ្ធភាពផ្នែកហិរញ្ញវត្ថុ
និងការធ្វើផែនការយុទ្ធសាស្ត្រ និងផែនការគ្រប់
គ្រងរយៈពេលវែងនិងមធ្យម

ត្រូវធ្វើការអនុវត្តជាចាំ។
ការធ្វើផែនការនៅតាមសហគមន៍មូលដ្ឋាន
កសិដ្ឋាន ឬកម្រិតស្រែគំរូ គប្បីទទួលបានការ
សម្របស្រួលដោយភ្នាក់ងារជាច្រើនដែលទទួ
លបានការបណ្តុះបណ្តាលនៅក្នុងផ្នែកកសិរុក្ខ
កម្ម (គោលការណ៍ទី 2) និងរួមបញ្ចូលនូវការជ្
រើសរើសជម្រើសនានាផ្នែកកសិរុក្ខកម្មដែលល្អ
បំផុតសម្រាប់បរិបទជាក់លាក់
ដោយគិតពិចារណាលើលក្ខខណ្ឌបរិស្ថាន
វប្បធម៌ ទីផ្សារ និងគោលនយោបាយ
(គោលការណ៍ទី 12)។

## 5.3. ការស្រាវជ្រាវ និងការរៀនសូត្រមិនចេះឈប់

ការសិក្សារៀនសូត្រនិងការស្រាវជ្រាវជាបន្តប
ន្ទាប់ គឺត្រូវការជាចាំបាច់សម្រាប់ការបង្កើតចំ
ណេះដឹងកសិរុក្ខកម្មរួមគ្នា មិនមែនគ្រាន់តែដើ
ម្បីបង្ហាញពីកិច្ចខិតខំប្រឹងប្រែងនិងកម្រិតនៃកា
រអនុវត្តល្អបំផុតប៉ុណ្ណោះទេ ប៉ុន្តែដើម្បីធ្វើការកែ
សម្រួលដល់ការអនុវត្តនិងបច្ចេកវិទ្យាកសិរុក្ខក
ម្មដែលមានស្រាប់ ដើម្បីធ្វើការដោះស្រាយចំ
ពោះការប្រែប្រួលនៅក្នុងបរិបទក្នុងស្រុក រួមទាំ
ងការផ្លាស់ប្តូរនាពេលអនាគតក្នុងរបបអាកាស
ធាតុ និងឥទ្ធិពលផ្សេងៗពីកត្តាខាងក្រៅ
(គោលការណ៍ទី 3, 12)។ ការរៀបចំឯកសារ
និងការពិនិត្យលើបណ្តុំភាពជោគជ័យនិងបរាជ័
យក្នុងអតីតកាល
និងគំរូកសិរុក្ខកម្មដែលមានស្រាប់ គឺជាការចា
ប់ផ្តើមដ៏ល្អដើម្បីផ្តល់អាទិភាពដល់ការស្រាវជ្
រាវក្នុងទិដ្ឋភាពផ្សេងៗផ្នែកកសិរុក្ខកម្ម។
ការស្រាវជ្រាវ គប្បីធ្វើឡើងទៅតាមសកម្មភាព
និងត្រូវអនុវត្តនៅក្នុងគំរូនៃការសិក្សាចែករំលែក
និងមានការចូលរួមពីភាគីពាក់ព័ន្ធ។ ផ្នែកនៃកិ
ច្ចដំណើរការក្នុងការធ្វើផែនការ គឺដើម្បីកំណត់

ពីស្ថាប័នស្រាវជ្រាវនិងស្ថាប័នសិក្សាធិការដែលពាក់ព័ន្ធ ឬចង់ចូលរួមនៅក្នុងការស្រាវជ្រាវកសិរុក្ខកម្ម និងការគាំទ្ររបស់ពួកគេដើម្បីសម្របសម្រួលដល់កិច្ចខិតខំប្រឹងប្រែងដើម្បីធានានូវការបំពេញ

បន្ថែមលើចំណុចខ្វះខាតជាជាងការធ្វើការខិតខំប្រឹងប្រែងស្រាវជ្រាវជាន់លើគ្នា។ ការបង្កើតកម្មវិធីសិក្សាផ្នែកកសិរុក្ខកម្ម គប្បីទទួលបានការគាំពារ ដើម្បីធានាថាកសិរុក្ខកម្ម គឺត្រូវបានបង្រៀននៅតាមស្ថាប័នឧត្តមសិក្សា ដែលកម្មវិធីសិក្សានេះត្រូវបានបង្កើតឡើងផ្អែកទៅតាមការងាររបស់បណ្តាញអាស៊ីអាគ្នេយ៍សម្រាប់ការអប់រំផ្នែកកសិរុក្ខកម្ម ដែលត្រូវបានបង្កើតឡើងដោយមជ្ឈមណ្ឌលកសិរុក្ខកម្មពិភពលោកនៅចុងទសវត្សរ៍ឆ្នាំ 1990 ដោយទទួលបានមូលនិធិពីទីភ្នាក់ងារអភិវឌ្ឍន៍អន្តរជាតិ ក៏ដូចជាបណ្តាញអប់រំនៅថ្នាក់ឧត្តមសិក្សាដទៃផ្សេងទៀតដែលមានស្រាប់នៅក្នុងតំបន់។ កិច្ចខិតខំប្រឹងប្រែងនេះ គប្បីត្រូវធ្វើឡើងស្របទៅតាមគោលដៅទូលំទូលាយរបស់រដ្ឋមន្ត្រីអប់រំអាស៊ីអាគ្នេយ៍នៃមជ្ឈមណ្ឌលសម្រាប់ការសិក្សាថ្នាក់ឧត្តមសិក្សានិងការស្រាវជ្រាវក្នុងផ្នែកកសិកម្មនៅតំបន់អាស៊ីអាគ្នេយ៍។

## 5.4. ការគ្រប់គ្រងតាមដាន និងការវាយតម្លៃ

ក្នុងទស្សនៈកសិរុក្ខកម្មធំៗបន្ថែមលើការចូលរួមចំណែកដើម្បីអនុវត្តអនុសញ្ញាក្របខណ្ឌសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុ គោលដៅមិនធ្វើឲ្យខូចដល់គុណភាពដី សន្តិសុខស្បៀង និងគោលដៅដទៃផ្សេងទៀត គោលដៅនិងយុទ្ធសាស្ត្រនានាដែលផ្នែកកសិរុក្ខកម្មចូលរួមចំណែក រដ្ឋជាសមាជិកអាស៊ាន អាចរួមបញ្ចូលនូវកសិរុក្ខកម្មនៅក្នុងគ្រោងការគ្រប់គ្រងតាមដាន រាយការណ៍ និងផ្ទៀងផ្ទាត់បញ្ជាក់។ ដំណើរការនៃការគ្រប់គ្រងតាមដានណាមួយ គប្បីត្រូវធានាថាគោលការណ៍ខាងក្រោម ត្រូវបានដោះស្រាយតាមរយៈកម្មវិធីកសិរុក្ខកម្ម៖

1) ការសិក្សារៀនសូត្រជាបន្តបន្ទាប់៖ កម្មវិធីនេះ គប្បីប្រកាន់ខ្ជាប់នូវកិច្ចដំណើរការដើម្បីទទួលបានមតិយោបល់ត្រឡប់ និងដើម្បីផ្តល់ព័ត៌មានដល់ភាគីពាក់ព័ន្ធ។ កម្មវិធីនេះ គប្បីមានលក្ខណៈសម្របសម្រួលនៅក្នុងការទទួលយកមតិយោបល់ត្រឡប់ដើម្បីធ្វើការកែលម្អសកម្មភាពនានា។

2) ការគ្រប់គ្រងតាមបែបចូលរួមនិងល្អសម្រាប់អ្នកប្រើប្រាស់៖ ការអភិវឌ្ឍឧបករណ៍តាមដាន គឺជាការអនុវត្តល្អបំផុតដើម្បីធានានូវភាពល្អប្រសើរសម្រាប់អ្នកប្រើប្រាស់។

3) ពង្រឹងសមត្ថភាពភាគីពាក់ព័ន្ធ៖ ការចូលរួមដែលមានប្រសិទ្ធភាព តម្រូវឲ្យមានសមត្ថភាពនិងជំនាញបច្ចេកទេស សង្គម និងហិរញ្ញវត្ថុ។ ការពង្រឹងសមត្ថភាព អាចបង្កើននូវការចូលរួមរបស់ភាគីពាក់ព័ន្ធនៅក្នុងការគ្រប់គ្រងតាមដាន ជាពិសេសជាមួយនឹងក្រុមគាំទ្រកសិករ និងក្រុមអ្នកប្រើប្រាស់ព្រៃឈើ

នៅកម្រិតអាស៊ាន ការគ្រប់គ្រងតាមដានការយល់ដឹងចំពោះក្របខណ្ឌនេះដោយរដ្ឋជាសមាជិក គប្បីត្រូវមានការសម្របសម្រួលដោយកម្មវិធីស្បៀងអាហារកសិកម្ម និងព្រៃឈើអាស៊ាន ដោយប្រើប្រាស់លិខិតឧបករណ៍ជាធរមានដែលត្រូវបានអនុម័តដោយអាស៊ាន ដូចជាការគ្រប់គ្រងរបស់អាស៊ានស្តីពីសន្តិសុខស្បៀង បរិស្ថាន និងការប្រែប្រួលអាកាសធាតុ។ ក្របខណ្ឌពហុវិស័យអាស៊ានស្តីពីការប្រែប្រួលអាកាសធាតុ៖ កសិកម្ម ជលផល រុក្ខាប្រម៉ាញ់ឆ្ពោះទៅរ

កសន្តិសុខស្បៀងក៏អាចត្រូវបានប្រើប្រាស់សម្រាប់ការគ្រប់គ្រងតាមដាននិងការវាយតម្លៃលើគោលការណ៍ណែនាំដោយរដ្ឋជាសមាជិក ជាពិសេសពាក់ព័ន្ធទៅនឹងកិច្ចសហប្រតិបត្តិការពហុវិស័យនៅក្នុងចំណោមរដ្ឋជាសមាជិក។

FAO ក៏អាចធ្វើការពិចារណាលើការគ្រប់គ្រងនិងការវាយតម្លៃវឌ្ឍនភាពនៃការអនុវត្តគោលការណ៍ណែនាំទាំងនេះដោយរដ្ឋជាសមាជិកអាស៊ានផងដែរ ដោយគិតពិចារណាលើមូលដ្ឋានទិន្ន័យសាកលស្តីពីគម្របរុក្ខជាតិ និងរុក្ខជាតិនៅក្រៅតំបន់ព្រៃ។

## 5.5. ការគ្រប់គ្រងចំណេះដឹង

បញ្ហាមួយក្នុងចំណោមបញ្ហាជាច្រើនដែលត្រូវបានលើកឡើងនៅក្នុងការអភិវឌ្ឍកសិរុក្ខកម្ម គឺកង្វះខាតប្រភពចំណេះដឹងនិងព័ត៌មាននៅក្នុងរដ្ឋជាសមាជិកអាស៊ាន។ ភាពជាប់ទាក់ទងគ្នា មិនមែនត្រឹមតែភាពខ្វះខាតផ្នែកស្ថាប័នក្នុងស្រុកសម្រាប់ការស្រាវជ្រាវនិងការអភិវឌ្ឍកសិរុក្ខកម្មនៅក្នុងរដ្ឋជាសមាជិកអាស៊ានប៉ុណ្ណោះទេ ក៏ប៉ុន្តែចំណេះដឹងកសិរុក្ខកម្ម ក៏តែងអាចស្វែងរកបានក្នុងទម្រង់ជាអត្ថបទស្រាវជ្រាវវិទ្យាសាស្រ្តដែរ ដែលការនេះពុំទាន់អាចស្វែងរកបានដោយអ្នកបង្កើតគោលនយោបាយនិងអ្នកធ្វើផែនការនៅឡើយទេ។ ពាក់ព័ន្ធនឹងគោលការណ៍ទី 13 ចំណេះដឹងកសិរុក្ខកម្ម ត្រូវចែករំលែកគ្នាដោយប្រសិទ្ធភាព ប៉ុន្តែចំណេះដឹងនេះ មិនអាចគ្រប់គ្រង និងបង្ហាញជូនដោយប្រសិទ្ធភាពបាននោះទេ លើកលែងតែមានការបែងចែកទំនួលខុសត្រូវច្បាស់លាស់ដល់អង្គភាពសមស្របប៉ុណ្ណោះ។ អាស្រ័យហេតុនេះបានជាវាមានការចាំបាច់សម្រាប់រដ្ឋជាសមាជិកអាស៊ានដើម្បីបង្កើតស្ថាប័នសម្រាប់គ្រប់គ្រងកសិរុក្ខកម្មឲ្យមានប្រសិទ្ធភាព និងធានាថាចំណេះដឹងនេះ អាចស្វែងរកបានជាស្រេចដល់អ្នកប្រើប្រាស់ជាច្រើន។ កិច្ចការនៃស្ថាប័ននេះ គឺដើម្បីធ្វើការប្រមូលនិងធ្វើ ចំណាត់ថ្នាក់ចំណេះដឹងកសិរុក្ខកម្ម បង្កើតហេដ្ឋារចនាសម្ព័ន្ធនៃកបច្ចេកវិទ្យា ដូចជាគេហទំព័រស្ថាប័ន និងការគ្រប់គ្រងអ្នកប្រើប្រាស់ (ភ្ជាប់ទៅនឹងការគ្រប់គ្រងតាមដាននិងការវាយតម្លៃផ្នែក 5.4)។ ការគ្រប់គ្រងចំណេះដឹងផ្នែកកសិរុក្ខកម្ម គឺជាការងារដែលអាចផ្តល់ជូនបានដោយស្ថាប័នទទួលខុសត្រូវ ឬស្ថាប័នបង្កើតថ្មី (សូមមើលគោលការណ៍ 1)។ ការងារនេះ អាចត្រូវបានចែករំលែកជាមួយម្ចាស់ចំណេះដឹងនិងអ្នកចែកចាយ ដូចជាស្ថាប័នស្រាវជ្រាវ និងបណ្ឌិតសភា ក៏ដូចជាអង្គការមិនមែនរដ្ឋាភិបាលផងដែរ។

# ឧបសម្ព័ន្ធ 1
# ការបង្កើតគោលការណ៍ណែនាំ

គំនិតក្នុងការបង្កើតគោលការណ៍ណែនាំអាស៊ានសម្រាប់ការអភិវឌ្ឍកសិរុក្ខកម្មកើតចេញពីទម្រង់នៃកិច្ចពិភាក្សាគ្នាជាច្រើនចាប់តាំងពីឆ្នាំ 2015 មក រវាងដៃគូនៃកម្មវិធីភាពជាដៃគូអាស៊ាន-ស្វីសសម្រាប់សហគមន៍ព្រៃឈើនិងការប្រែអាកាសធាតុ ក្រុមការងារអាស៊ានស្តីពីព្រៃឈើសហគមន៍ និងអង្គភាពស្បៀងអាហារកសិកម្ម និងរុក្ខាប្រម៉ាញ់នៃអគ្គលេខាធិការអាស៊ាន ដែលត្រូវបានបង្កើតឡើងនិងផ្សព្វផ្សាយដោយការជ្រើសរើសចក្ខុវិស័យ និងផែនការយុទ្ធសាស្រ្តសម្រាប់កិច្ចសហប្រតិបត្តិការអាស៊ានផ្នែកចំណីអហារ កសិកម្ម និងរុក្ខាប្រម៉ាញ់ ឆ្នាំ2016-2025។ ជាពិសេស ផែនការនេះ កំណត់ពីកសិរុក្ខកម្មនៃកម្មវិធីសកម្មភាពដើម្បីសម្រេចបាននូវសន្តិសុខស្បៀងនៅក្នុងការប្រឈមនឹងការប្រែប្រួលអាកាសធាតុ។ ខណៈដែលតួនាទីនិងការរួមចំណែករបស់កសិរុក្ខកម្មនៅផ្នែកទាំងនេះ គឺឃើញមានការកើនឡើងនៅក្នុងយុទ្ធសាស្រ្តនិងផែនការសកម្មភាពជាតិពាក់ព័ន្ធនឹងសន្តិសុខស្បៀងនិងអាហារូបត្ថម្ភ ការប្រែប្រួលអាកាសធាតុ ការអភិវឌ្ឍបៃតង និងការអភិវឌ្ឍប្រកបដោយចីរភាព ការអនុវត្តដែលបង្កជាបញ្ហាប្រឈមនានា ដោយសារកសិរុក្ខកម្មពុំមានស្ថាប័នផ្ទាល់ខ្លួននៅក្នុងប្រទេសនីមួយៗនោះទេ។ ការសិក្សាជាច្រើនបានបង្ហាញថា ក្រៅពីបញ្ហានៃការធ្វើសេចក្តីសម្រេចចិត្តរបស់កសិករ និងបញ្ហាប្រឈមនៅកម្រិតកសិដ្ឋាន ឧបសគ្គសំខាន់នោះ គឺកង្វះខាតការគាំទ្រផ្នែកគោលនយោបាយច្បាស់លាស់និង

យន្តការចែករំលែកនៅក្នុងរដ្ឋជាសមាជិកអាស៊ាន។ ដើម្បីដោះស្រាយបញ្ហានេះ គោលការណ៍ណែនាំកម្រិតអាស៊ាន ត្រូវបង្កើតឡើងជាចាំបាច់ដើម្បីបង្កើតនូវគោលការណ៍និងគោលការណ៍ណែនាំដែលអាចគាំទ្រដល់ការអភិវឌ្ឍគោលនយោបាយ កម្មវិធី និងការ វិនិយោគផ្នែកកសិរុក្ខកម្មយ៉ាងឆាប់រហ័ស។

នៅក្នុងសិក្ខាសាលាភាគីពាក់ព័ន្ធលើកដំបូង ត្រូវបានរៀបចំឡើងនៅទីក្រុងឈៀងម៉ៃ ប្រទេសថៃនៅខែមិថុនា ឆ្នាំ2016 ដែលគេបានឯកភាពថា គោលការណ៍ណែនាំត្រូវបង្កើតឡើងដោយផ្តាច់មុខតាមដែលអាចធ្វើទៅបាន ដោយរួមបញ្ចូលនូវអ្នកស្រាវជ្រាវ អ្នកបណ្តុះបណ្តាល អ្នកអប់រំ អ្នកបង្កើតផែនការ អ្នកអនុវត្តការងារ និងអ្នកបង្កើតគោលនយោបាយ។ បន្ថែមលើនេះ គេបានឯកភាពថា គោលការណ៍ណែនាំ គប្បីមានលក្ខណៈដាច់ណាត់និងមានភាពសកម្មនៅក្នុងផ្នែកភាសានិងរចនាសម្ព័ន្ធ ប៉ុន្តែពុំមានព័ត៌មានលម្អិតច្រើន ដែលអនុញ្ញាតឲ្យមានភាពច្នៃប្រឌិត និងនវានុវត្តន៍ ក្នុងអំឡុងពេលនៃការអនុវត្តនោះ។ ចាប់តាំងពីខែមិថុនា ឆ្នាំ2017 កិច្ចដំណើរការនៃភាគីពាក់ព័ន្ធពហុភាគី បានរួមបញ្ចូលនូវសកម្មភាពគន្លឹះសំខាន់ៗ ដែលមានរៀបរាប់ដូចខាងក្រោម។

1) ការប្រឹក្សាយោបល់របស់ភាគីពាក់ព័ន្ធដែលមានសិក្ខាកាមចំនួនប្រហែល 245 នាក់ មកពីរដ្ឋជាសមាជិកអាស៊ាន រួមទាំងអ្នកបង្កើតគោលនយោបាយ ក្រុមកសិករនិងសហករ ក្រុមគ្រប់គ្រងព្រៃឈើនៅតាមតាមសហគមន៍ អ្នកអនុវត្តការងារ និងអ្នកស្រាវជ្រាវនៅក្ន

ងសន្និសីទលើកទី 7 របស់ក្រុមការងារអាស៊ានស្តីពីព្រៃឈើសហគមន៍ ដែលរៀបចំឡើងនៅក្នុងទីក្រុងឈៀងម៉ៃ ប្រទេសថៃ ពីថ្ងៃ12-14 ខែមិថុនា ឆ្នាំ2017។ ការពិភាក្សាពិគ្រោះយោបល់ផ្តោតជាសំខាន់លើគោលបំណងនិងខ្លឹមសារទូទៅនៃគោលការណ៍ណែនាំនេះ។

2) ការធ្វើបទបង្ហាញ និងការទទួលយកនូវកំណត់ទស្សនាទានសម្រាប់ការបង្កើតគោលការណ៍ណែនាំនៅក្នុងកិច្ចប្រជុំប្រចាំឆ្នាំលើកទី 11 របស់ក្រុមការងារអាស៊ានស្តីពីព្រៃឈើសហគមន៍ ដែលរៀបចំឡើងនៅទីក្រុងឈៀងម៉ៃ ប្រទេសថៃ នៅថ្ងៃទី15 ខែមិថុនា ឆ្នាំ2017។

3) ការប្រគល់ផែនការការងារសម្រាប់ការបង្កើតគោលការណ៍ណែនាំជូនដល់ក្រុមការងារអាស៊ានស្តីពីលេខាធិការដ្ឋានព្រៃឈើសហគមន៍នៅក្នុងខែមិថុនា ឆ្នាំ2017។

4) ការត្រៀមរៀបចំសម្រាប់គោលការណ៍ណែនាំ "សេចក្តីព្រាងដែលមានគ្មានផលប៉ះពាល់" ដោយ ICRAF និង FAO ពីខែមិថុនា ដល់ខែសីហា ឆ្នាំ2017។

5) ការត្រៀមរៀបចំនៃសេចក្តីព្រាងលើកទីមួយពី ខែសីហាដល់ខែធ្នូ ឆ្នាំ2017។

6) ការត្រួតពិនិត្យដោយដៃគូលើសេចក្តីព្រាងលើកទីមួយដោយភាពជាដៃគូអាស៊ាន-ស្វីសសម្រាប់ព្រៃឈើសហគមន៍ និងការប្រែប្រួលអាកាសធាតុ អគ្គលេខាធិការអាស៊ាន និង FAO ពីខែធ្នូ ឆ្នាំ2017 ដល់ខែមករា ឆ្នាំ2018។

7) ការត្រួតពិនិត្យសេចក្តីព្រាងលើកទីមួយដោយអ្នកជំនាញកសិរុក្ខកម្ម រួមទាំងក្រុមអ្នកជំនាញមេគង្គស្តីពីកសិរុក្ខកម្មសម្រាប់សន្តិសុខស្បៀង និងអាហារូបត្ថម្ភ កសិកម្មប្រកបដោយនិរន្តរភាព និងការស្តារលទ្ធភាពដី និងក្រុមការងារអាស៊ានស្តីពីព្រៃឈើសហគមន៍ នៅខាងក្នុងនិងខាងក្រៅតំបន់ នៅថ្ងៃទី2 ខែមករា ឆ្នាំ2018។

8) ការរៀបចំសេចក្តីព្រាងទីពីរ ខែមករា-កុម្ភៈ ឆ្នាំ2018។

9) ការត្រួតពិនិត្យសេចក្តីព្រាងទីពីរដោយក្រុមការងារអាស៊ានតាមវិស័យ ខែកុម្ភៈ-មីនា ឆ្នាំ2018។

10) ការត្រួតពិនិត្យសេចក្តីព្រាងទីពីរដោយក្រុមការងារអាស៊ានស្តីពីព្រៃឈើសហគមន៍ នៅក្នុងខែកុម្ភៈ-មេសា ឆ្នាំ2018។

11) ការសម្រេចចុងក្រោយនៃសេចក្តីព្រាងទីពីរ ខែមេសា-ឧសភា ឆ្នាំ2018។

12) ការពិភាក្សានិងការធ្វើសេចក្តីសម្រេចចុងក្រោយនៅក្នុងកិច្ចប្រជុំលើកទី 12 របស់ក្រុមការងារអាស៊ានស្តីពីព្រៃឈើសហគមន៍នៅក្នុងទីក្រុងដាណាំង ប្រទេសវៀតណាម ក្នុងខែមិថុនា ឆ្នាំ2018។

# ឧបសម្ព័ន្ធ 2 ម្រេចស:

## កសិរុក្ខកម្ម៖ ការរួមចំណែកចំពោះសន្តិសុខស្បៀងនិង ការបន្សាំនិងការកាត់បន្ថយការប្រែប្រួលអាកាសធាតុនៅក្នុងតំបន់អាស៊ីអាគ្នេយ៍[12]




អាស៊ីអាគ្នេយ៍ កំពុងឆ្លងកាត់កំណើនសេដ្ឋកិច្ចខ្ពស់ដោយមានអត្រាកំណើនជាមធ្យម 5.7% នៃចំនួន GDP និងបានសម្រេចនូវគោលដៅអភិវឌ្ឍន៍សហសវត្សរ៍ ដោយបានកាត់បន្ថយចំនួនប្រជាជនអត់ឃ្លានជិតពាក់កណ្តាល។ ខណ:ដែលមានសមិទ្ធិផលយ៉ាងច្រើនដែលសម្រេចបានប៉ុន្តែប្រជា

ជន 60 លាននាក់ (>10% នៃប្រជាជនសរុប) កំពុងស្ថិតនៅក្នុងស្ថានភាពអសន្តិសុខផ្នែកស្បៀងអាហារ។ កំណើនប្រជាជនយ៉ាងឆាប់រហ័ស រួមគ្នាជាមួយការចុះថយផ្នែកគុណភាពដី

12 ម្រេចសនៅក្នុងផ្នែកកសិរុក្ខកម្ម បានរំលេចឲ្យឃើញពីគោលគំនិតពាក់ព័ន្ធនឹងកសិរុក្ខកម្ម ការអនុវត្តកសិរុក្ខកម្មដែលអនុម័តដោយអាស៊ីអាគ្នេយ៍ ការរួមចំណែកដល់សន្តិសុខស្បៀង ប្រាក់ចំណូល និងនិយ័តកម្មទឹក ការបន្សាំនិងការកាត់បន្ថយការប្រែប្រួលអាកាសធាតុ បញ្ហានិងបញ្ហាប្រឈម ឧបសគ្គផ្នែកគោលនយោបាយ និងការស្នើសុំឲ្យមានចាត់វិធានការដោយរដ្ឋជាសមាជិកអាស៊ាន។

អាចបណ្តាលឲ្យប្រទេសជាច្រើននៅក្នុងតំបន់ខកខានក្នុងបំពេញតាមតម្រូវការនៃការស្រេកឃ្លានរបស់ប្រជាជនរបស់ពួកគេនៅក្នុងពេលអនាគត។

ការប្រែប្រួលអាកាសធាតុ គឺជាការគំរាមកំហែងបន្ថែមដល់ការទិដ្ឋភាពនៃការផ្គត់ផ្គង់សន្តិសុខស្បៀង។ ស្របទៅតាមផ្នែកអន្តររដ្ឋាភិបាលស្តីពីរបាយការណ៍វាយតម្លៃលើកទីបួននៃការប្រែប្រួលអាកាសធាតុ តំបន់អាស៊ីអាគ្នេយ៍ ត្រូវបានរំពឹងថានឹងរងផលប៉ះពាល់យ៉ាងធ្ងន់ធ្ងរដោយការប្រែប្រួលអាកាសធាតុដោយសារសេដ្ឋកិច្ចត្រូវពឹងផ្អែកលើកសិកម្មនិងធនធានធម្មជាតិ។

កសិរុក្ខកម្ម ដែលជាការអនុវត្តដាំដុះរុក្ខជាតិនៅក្នុងដីកសិដ្ឋាន និងការរួមបញ្ចូលព្រៃឈើនិងកសិកម្មជាផ្នែកនៃតំបន់ទេសភាពពហុមុខងារ អាចផ្តល់នូវអត្ថប្រយោជន៍ជាច្រើនផ្នែកសេដ្ឋកិច្ច សង្គម និងបរិស្ថាន។ នៅក្នុងការប្រៀបធៀបជាសាកលមួយ តំបន់អាស៊ីអាគ្នេយ៍ មានស្តុកកាបូនជីវម៉ាសខ្ពស់ជាងគេ (ក្នុងមួយហិចតា) នៅលើដីកសិកម្មក្នុងចំណោមតំបន់ទាំងអស់ ដោយមានទំនោរកើនឡើង (60 តោនកាបូនក្នុងមួយហិចតាក្នុងឆ្នាំ2000 និង 65 តោនក្នុងមួយហិចតា ក្នុងឆ្នាំ2010)។ កសិករនៅផ្នែកដទៃផ្សេងទៀតនៃតំបន់នេះ បានកំពុងជ្រើសរើសយកប្រព័ន្ធកសិរុក្ខកម្មផ្សេងៗ និងការអនុវត្តនានា

ដោយបង្កើនផលិតភាពដីកសិកម្ម និងការជួយធានាសន្តិសុខស្បៀង ប្រាក់ចំណូល និងតម្រូវការជាមូលដ្ឋានដទៃផ្សេងទៀត។ នៅពេលជាមួយគ្នានោះដែរ ចំនួនយ៉ាងច្រើននៃការស្រូបយកកាបូនដោយរុក្ខជាតិនៅក្នុងប្រព័ន្ធកសិរុក្ខកម្ម គឺរួមចំណែកដល់ការកាត់បន្ថយផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ ខណៈដែលព្រៃឈើ និងរុក្ខជាតិដើរតួនាទីជា "ម៉ាស៊ីនត្រជាក់" សម្រាប់ធ្វើឲ្យមជ្ឈដ្ឋានជុំវិញត្រជាក់ និងបញ្ជូនចំហាយទឹកត្រឡប់ទៅកាន់បរិយាកាសវិញ។ ក៏ប៉ុន្តែ ការជ្រើសរើសយកកសិរុក្ខកម្មទ្រង់ទ្រាយធំ នៅតែមានកម្រិតនៅឡើយ ដោយសារមានបញ្ហាប្រឈមនិងឧបសគ្គជាច្រើន ជាពិសេសកង្វះខាតស្ថាប័នក្នុងស្រុកនិងគោលនយោបាយជាក់លាក់សម្រាប់គាំទ្រដល់ផ្នែកកសិរុក្ខកម្ម។ ដើម្បីសម្រេចបាននូវសក្តានុពលនៃកសិរុក្ខកម្មនៅក្នុងផ្នែកសន្តិសុខស្បៀងនិងអាកាសធាតុ ការបន្សាំនិងការកាត់បន្ថយការប្រែប្រួលអាកាសធាតុនៅតំបន់អាស៊ីអាគ្នេយ៍ គោលនយោបាយកសិរុក្ខកម្ម និងយន្តការចែករំលែកប្រកបដោយប្រសិទ្ធភាព ត្រូវការមានជាចាំបាច់។

# ឧបសម្ព័ន្ធ 3 បរិបទអន្តរជាតិនៃគោលការណ៍ណែនាំនេះ

គោលការណ៍ណែនាំនេះ ស្របគ្នាជាមួយនឹងអនុសញ្ញាអន្តរជាតិ កិច្ចព្រមព្រៀង និងសន្ធិសញ្ញាដែលមានភ្ជាប់កាតព្វកិច្ចផ្លូវច្បាប់និងពុំមានភ្ជាប់កាតព្វកិច្ចផ្លូវច្បាប់ទាំងអស់ ក៏ដូចជាកម្មវិធីនិងក្របខណ្ឌសាកលដែលរដ្ឋជាសមាជិកអាស៊ានបានប្តេជ្ញាចិត្តអនុវត្ត។ គោលការណ៍ណែនាំនេះ រួមបញ្ចូលនូវចំណុចជាអាទិ៍ដូចខាងក្រោម។

- 17 គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព ត្រូវបានអនុម័តដោយថ្នាក់ដឹកនាំពិភពលោកនៅក្នុងខែកញ្ញា ឆ្នាំ2015។ ដោយឈរលើមូលដ្ឋាននៃភាពជោគជ័យនៃគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព គោលដៅសំខាន់គឺការកៀងគរកិច្ចខិតខំប្រឹងប្រែងដើម្បីបញ្ឈប់រាល់ទម្រង់ទាំងអស់នេះ ភាពក្រីក្រ ការប្រយុទ្ធប្រឆាំងនឹងវិសមភាព និងការដោះស្រាយបញ្ហាការប្រែប្រួលអាកាសធាតុ និងធានាថា "គ្មានអ្នកណាម្នាក់ត្រូវទុកចោលនោះទេ"។
- អនុសញ្ញានៃក្របខណ្ឌអង្គការសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុ (UNFCCC) មានគោលបំណងក្នុងការរក្សាតុល្យភាពបរិមាណឧស្ម័នផ្ទះកញ្ចក់នៅក្នុងបរិយាកាសដើម្បីការពារការរំខានដែលមានគ្រោះថ្នាក់ដល់ប្រព័ន្ធអាកាសធាតុ ដោយពុំមានភ្ជាប់កាតព្វកិច្ចនៃការដាក់កំហិតលើឧស្ម័នផ្ទះកញ្ចក់ ឬយន្តការពង្រឹងការអនុវត្តសម្រាប់បណ្តាប្រទេសផ្សេងៗ។
- ក្របខណ្ឌនេះ បង្ហាញពីរបៀបដែលសន្ធិសញ្ញាអន្តរជាតិជាក់លាក់ (ហៅថាពិធីសារ ឬកិច្ចព្រមព្រៀង) អាចត្រូវបានពិភាក្សាដើម្បីបញ្ជាក់បន្ថែមលើសកម្មភាពឆ្ពោះទៅរកកម្មវត្ថុរបស់អង្គការ UNFCCC។
- កិច្ចព្រមព្រៀងទីក្រុងបារីស កើតចេញពីការចរចារបស់អង្គការ UNFCCC និងមានគោលបំណងក្នុងការជំរុញកិច្ចខិតខំប្រឹងជាសាកលដើម្បីធ្វើឲ្យសីតុណ្ហភាពចុះទាបរហូតដល់ 1.5℃ លើសពីកម្រិតមុនយុគសម័យឧស្សាហកម្ម បង្កើនសមត្ថភាពក្នុងការទទួលយកជំរុញភាពធន់ទ្រាំផ្នែកអាកាសធាតុ និងការអភិវឌ្ឍដែលបញ្ចេញឧស្ម័នផ្ទះកញ្ចក់ទាបដោយពុំមានការគំរាមកំហែងដល់ផលិតផលស្បៀង និងបង្កើតលំហូរហិរញ្ញវត្ថុដែលគាំទ្រដល់គោលបំណងទាំងនេះ។ តាមរយៈការចូលរួមចំណែកដើម្បីអនុវត្តអនុសញ្ញាក្របខណ្ឌសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុ ប្រទេសមួយចំនួនបានបង្កើតសកម្មភាពស្របគ្នាដោយខ្លួនឯងទៅតាមកាលៈទេសៈ សមត្ថភាព និងចំណុចអាទិភាពនានារបស់ជាតិ។

- អនុសញ្ញាស្តីពីជីវៈចម្រុះ (CBD) បង្ហាញពីគោលការណ៍ដែលគ្រប់គ្រងលើអនុសញ្ញាស្តីពីជីវៈចម្រុះ ការប្រើប្រាស់ប្រកបដោយចីរភាពនៃសមាសភាព និង ការចែករំលែកដោយស្មើភាពគ្នានៃអត្ថប្រយោជន៍នានាដែលកើតឡើងចេញពីធនធានសេនេទិក។
- អនុសញ្ញាអង្គការសហប្រជាជាតិដើម្បីប្រយុទ្ធប្រឆាំងនឹងវាលរហោស្ថានកម្ម (UNCCD) គឺជាយុទ្ធសាស្ត្ររយៈពេល 10 ឆ្នាំ (2008-2018) ដែលមានគោលដៅបង្កើតភាពជាដៃគូសាកលដើម្បីកែប្រែ និងបង្ការការរីករាលដាលវាលរហោដ្ឋាននិងសំណឹកដី និងដើម្បីកាត់បន្ថយផលប៉ះពាល់នៃគ្រោះរាំងស្ងួត ដើម្បីគាំទ្រដល់ការកាត់បន្ថយភាពក្រីក្រនិងនិរន្តរភាពបរិស្ថាន។ អង្គការ UNCCD បានធ្វើកិច្ចសហប្រតិបត្តិការយ៉ាងជិតស្និទ្ធជាមួយ CBD និងអង្គការ UNFCCC ដើម្បីបំពេញតាមតម្រូវការនៃបញ្ហាប្រឈមស្មុគស្មាញ ជាមួយនឹងវិធីសាស្ត្ររួមផ្សំនិងការប្រើប្រាស់ធនធានធម្មជាតិល្អបំផុតតាមដែលអាចធ្វើទៅបាន។
- បញ្ហាប្រឈម គឺកិច្ចខិតខំប្រឹងប្រែងជាសាកលដើម្បីស្តារឡើងវិញនូវផ្ទៃដី 150 លានហិចតានៃផ្ទៃដីដែលរងការកាប់បំផ្លាញព្រៃឈើ និងដីដែលបាត់បង់គុណភាព នៅត្រឹមឆ្នាំ2020 និង 350 លានហិចតានៅត្រឹមឆ្នាំ2030 ដើម្បីសម្រេចបាននូវការប្តេជ្ញាចិត្តជាអន្តរជាតិដែលមានស្រាប់ រួមទាំងគោលដៅ CBD Aichi Target 15, UNFCCC REDD+, និង Rio+20 គោលដៅកាត់បន្ថយការកាត់បន្ថយគុណភាពដីជាដើម។
- អនុសញ្ញាទីក្រុងរាមសារស្តីពីតំបន់ដីសើម គឺសន្ធិសញ្ញាអន្តររដ្ឋាភិបាល ដោយផ្តល់នូវក្របខណ្ឌមួយសម្រាប់វិធានការថ្នាក់ជាតិ និងកិច្ចសហប្រតិបត្តិការនៅក្នុងកិច្ចសន្ទនានិងការប្រើប្រាស់តំបន់ដីសើមនិងធនធានរបស់ខ្លួន។
- សេចក្តីប្រកាសរបស់ទីក្រុងរីអូស្តីពីបរិស្ថាននិងការអភិវឌ្ឍ មានរៀបរាប់លម្អិតពីគោលការណ៍នេះដល់បណ្តាប្រទេសនានានៅក្នុងការធ្វើឲ្យមានតុល្យភាពបរិស្ថាននិងតុល្យភាពក្នុងការអភិវឌ្ឍនៅក្នុងគោលនយោបាយនិងវិធានការនានា។
- ក្រុមប្រតិបត្តិនៃការប្រមូល និងការផ្ទេរជីវករ គឺជាក្របខណ្ឌស្ម័គ្រចិត្តដែលផ្តល់ជូនសម្រាប់ការប្រមូលដែលសមស្របនិងការប្រើប្រាស់ប្រកបដោយចីរភាពនៃធនធានសេនេទិក។
- កិច្ចពិភាក្សាអន្តរជាតិស្តីពីសកម្មភាពសំណើរព្រៃឈើសម្រាប់ការគ្រប់គ្រងព្រៃឈើប្រកបដោយនិរន្តរភាព។
- ផែនការសកម្មភាពសាកលសម្រាប់អនុសញ្ញានិងការប្រើប្រាស់ប្រកបដោយនិរន្តរភាពនៃធនធានសេនេទិករុក្ខជាតិ គឺជាក្របខណ្ឌសាកលស្ម័គ្រចិត្តមួយដែលផ្តល់ជូននូវការអភិវរក្សនិងការប្រើប្រាស់ប្រកបដោយនិរន្តរភាពនៃធនធានសេនេទិករុក្ខជាតិសម្រាប់ស្បៀងនិងកសិកម្ម។
- សេចក្តីប្រកាសសហសវត្សរ៍ និងគោលដៅអភិវឌ្ឍន៍សហសវត្សរ៍ មានគោលដៅក្នុងការលើកកម្ពស់ភាពថ្លៃថ្នូរនិងសមភាពរបស់មនុស្ស លុបបំបាត់ភាពក្រីក្រ ការពារបរិស្ថានរួមគាំទ្រសិទ្ធិមនុស្សនិងលទ្ធិប្រជាធិបតេយ្យ លើកកម្ពស់សមភាពយេនឌ័រ និងអភិបាលកិច្ចល្អ និងបង្កើតភាពជាដៃគូសម្រាប់ការអភិវឌ្ឍ។

- ក្របខណ្ឌទីក្រុងស៊ិនដៃ សម្រាប់ការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ (2015-2030) មានគោលបំណងដើម្បីសម្រេចបាននូវការកាត់បន្ថយហានិភ័យគ្រោះថ្នាក់និងការបាត់បង់អាយុជីវិត ជីវភាពរស់នៅ និងសុខភាព។ ក្របខណ្ឌនេះត្រូវបានអនុម័តដោយសន្និសីទ

# ឧបសម្ព័ន្ធ 4 ឯកសារជំនួយបន្ថែម


Burke L, Ranganathan J, Winterbottom R, eds. 2015. *Revaluing ecosystems: pathways for scaling up the inclusion of ecosystem value in decision making*. Washington DC, USA: World Resources Institute.

Catacutan D, McGaw E, Llanza MA, eds. 2014. *In equal measure: a user guide to gender analysis in agroforestry.* Bogor, Indonesia: World Agroforestry Centre (ICRAF) Southeast Asia Regional Program.

Colfer CJP, Achdiawan R, Roshetko JM, Mulyoutami E, Yuliani EL, Mulyana A, Moeliono M, Adnan H, Erni. 2015. The balance of power in household decision-making: encouraging news on gender in Southern Sulawesi. *World Development* 76:147–164.

Coe R, Sinclair F, Barrios E. 2014. Scaling up agroforestry requires research 'in' rather than 'for' development. *Current Opinion in Environmental Sustainability* 6:1877–3435. https://doi.org/10.1016/j.

Delaney M, Roshetko JM. 1999. Field test of carbon monitoring methods for home gardens in Indonesia. In: *Field tests of carbon monitoring methods in forestry projects*. Arlington VA, USA: Winrock International. pp 231–245. http://www.worldagroforestry.org/region/sea/publications/detail?pubID=4214.

[FAO] Food and Agriculture Organization of the United Nations. 2017. *Agroforestry for landscape restoration: Exploring the potential of agroforestry to enhance the sustainability and resilience of degraded landscapes*. Rome, Italy: Food and Agriculture Organization of the United Nations.

[FAO] Food and Agriculture Organization of the United Nations. 2013. *Advancing agroforestry on the policy agenda: a guide for decision-makers*. Agroforestry Working Paper No.1. Rome, Italy: Food and Agriculture Organization of the United Nations.

[FAO] Food and Agriculture Organization of the United Nations. 2011. *Payments for ecosystem services and food security*. Rome, Italy: Food and Agriculture Organization of the United Nations.

Klapwijk CJ, van Wijk MT, Rosenstock TS, van Asten PJA, Thornton PK, Giller KE. 2014. Analysis of trade-offs in agricultural systems: current status and way forward. *Current Opinion in Environmental Sustainability* 6:110–115. https://www.sciencedirect.com/science/article/pii/S1877343513001607.

Kuyah S, Öborn I, Jonsson M, Dahlin AS, Barrios E, Muthuri C, Malmer A, Nyaga J, Magaju C, Namirembe A, Nyberg Y, Sinclair FL. 2016. Trees in agricultural landscapes enhance provision of ecosystem services in Sub-Saharan Africa. *International Journal of Biodiversity Science, Ecosystem Services & Management* 12:4:255–273. http://www.

tandfonline.com/doi/full/10.1080/21513732.2016.1214178.

Martini E, Roshetko JM, Purnomosidhi P, Tarigan J, Idris N, Zulfadhli T. 2013. Fruit germplasm resources and demands for small-scale farmer's post-tsunami and conflicts in Aceh, Indonesia. *Acta Horticultura (ISHS)* 975:657–664. http://www.actahort.org/books/975/975_82.htm.

Manurung GE, Roshetko JM, Budidarsono S, Kurniawan I. 2008. Dudukuhan tree farming systems in West Java: how to mobilize self-strengthening of community-based forest management? In: Snelder DJ, Lasco R, eds. *Smallholder tree growing for rural development and environmental services. Lessons from Asia*. Advances in Agroforestry vol. 5. Dordrecht, Netherlands: Springer.

Mead DJ. 2004. Agroforestry. In: *Forests and forest plants*. Vol. 1. *Encyclopedia of life science systems*. Oxford, UK: EOLSS Publishers. pp 324–55.

Millennium Ecosystem Assessment. 2005. *Ecosystems and human well-being: synthesis*. Washington DC, USA: Island Press.

Minang PA, van Noordwijk M, Freeman OE, Mbow C, de Leeuw J, Catacutan D, eds. *Climate-smart landscapes: multifunctionality in practice*. Nairobi, Kenya: World Agroforestry Centre (ICRAF).

Nair PVR, Garrity DPN. 2012. *Agroforestry: the future of global land use*. Dordrecht, Netherlands: Springer.

Namirembe S, Leimona B, van Noordwijk M, Minang P, eds. 2017. *Co-investment in ecosystem services: global lessons from payment and incentive schemes.* Nairobi, Kenya: World Agroforestry Centre (ICRAF). http://www.worldagroforestry.org/sd/environmental-services/PES).

Neyra-Cabatac NM, Pulhin JM, Cabanilla DB. 2012. Indigenous agroforestry in a changing context: the case of the Erumanen ne Menuvu in Southern Philippines. *Forest Policy & Economics* 22:18–27.

[OECD] Organization for Economic Co-operation and Development. 2011. *Towards green growth: a summary for policy makers*. Paris, France: Organization for Economic Co-operation and Development.

Orwa C, Mutua A, Kindt R, Jamnadass R, Simons A. 2009. *Agroforestree Database: a tree reference and selection guide. Version 4.0.* Nairobi, Kenya: World Agroforestry Centre (ICRAF). http://www.worldagroforestry.org/output/agroforestree-database.

Perdana A, Budidarsono S, Kurniawan I, Roshetko JM. 2013. Rapid Market Appraisal (RMA). In: van Noordwijk M, Lusiana B, Leimona B, Dewi S, Wulandari D, eds. *Negotiation-support toolkit for learning landscapes*. Bogor, Indonesia: World Agroforestry Centre (ICRAF) Southeast Asia Regional Program. pp 52–54. http://www.worldagroforestry.org/downloads/Publications/PDFS/B17645.pdf.

Roshetko JM, Snelder DJ, Lasco RD, van Noordwijk M. 2008. Future challenge: a paradigm shift in the forestry sector. In: Snelder DJ, Lasco R, eds. *Smallholder tree growing for rural development and environmental services. Lessons from Asia.* Advances in Agroforestry vol. 5. Dordrecht, Netherlands: Springer. pp 453–485.

Roshetko JM, Rohadi D, Perdana A, Sabastian G, Nuryartono N, Pramono AA, Widyani N, Manalu P, Fauzi MA, Sumardamto P, Kusumowardhani N. 2013. Teak agroforestry systems for livelihood enhancement, industrial timber production, and environmental rehabilitation. *Forests, Trees, and Livelihoods* 22 (4):241–256. DOI: 10.1080/14728028.2013.855150.

Van der Wolf J, Gram G, Bukomeko H, Mukasa D, Giller O, Kirabo E, Angebault C, Vaast P, Asare R, Jassogne L. 2017. *The shade tree advice tool.* CCAFS Info Note. Copenhagen, Denmark: CGIAR Research Program on Climate Change, Agriculture and Food Security. https://ccafs.cgiar.org/publications/shade-tree-advice-tool#.WjjWDjcxXD4. Tool: http://shadetreeadvice.org/.

Van der Wolf J, Jassogne L, Gram G, Vaast P. 2016. Turning local knowledge on agroforestry into an online decision-support tool for tree selection in smallholders' farms. *Experimental Agriculture* 1–17. http://dx.doi.org/10.10107/S001447971600017X.

Van Noordwijk M. 2005. *RUPES typology of environmental service worthy of reward*. Bogor, Indonesia: World Agroforestry Centre (ICRAF) Southeast Asia Regional Program. http://www.worldagroforestry.org/downloads/Publications/PDFS/wp13952.pdf

Van Noordwijk M, Coe R, Sinclair F. 2016. *Central hypotheses for the third agroforestry paradigm within a common definition.* Working paper 233. Bogor, Indonesia: World Agroforestry Centre (ICRAF) Southeast Asia Regional Program. DOI: http://dx.doi.org/10.5716/WP16079.PDF.

Van Noordwijk M, Mbow C, Minang PA. 2015. *Trees as nexus for Sustainable Development Goals (SDG's): agroforestry for integrated options*. Policy Brief 50. Nairobi, Kenya: ASB Partnership for the Tropical Forest Margins.

Van Noordwijk M, Tata HL, Xu J, Dewi S, Minang PA. 2012. Segregate or integrate for multifunctionality and sustained change through rubber-based agroforestry in Indonesia and China. In: Nair PVR, Garrity DPN. *Agroforestry: the future of global land use.* Dordrecht, Netherlands: Springer. pp 69–104.

Visco R. 2011. *National case study on agroforestry policy in the Philippines.* Final report. Rome, Italy: Food and Agriculture Organization of the United Nations.

Wangpakapattanawong P, Finlayson R, Öborn I, Roshetko JM, Sinclair F, Shono K, Borelli S, Hillbrand A, Conigliaro M. 2017. *Agroforestry in rice-production landscapes in Southeast Asia: a practical manual.* Bangkok, Thailand: Food and Agriculture Organization of the United Nations Regional Office for Asia and the Pacific, Bogor, Indonesia: World Agroforestry Centre (ICRAF) Southeast Asia Regional Program.

Zomer RJ, Neufeldt H, Xu J, Ahrends A, Bossio D, Trabucco A, van Noorwijk M, Wang M. 2016. Global tree cover and biomass carbon on agricultural land: the contribution of agroforestry to global and national carbon budgets. *Scientific Reports* 6:1–12.


BHINNEKA TUNGGAL IKA
BERSEKUTU
BERTAMBAH MUTU
REPUBLIKA NG PILIPINAS
MAJULAH SINGAPURA
VIỆT NAM

World Agroforestry

AWG-SF
ASEAN Working Group on Social Forestry

Schweizerische Eidgenossenschaft
Confédération suisse
Confederazione Svizzera
Confederaziun svizra

Swiss Agency for Development
and Cooperation SDC

www.asean.org ASEAN ASEAN @ASEAN ASEAN